

# គម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ

## ការពិនិត្យឡើងវិញនូវស្ថានភាពរស់នៅរបស់ម្តាយ ស្រ្តីមានផ្ទៃពោះ និងកុមារតូចៗ

## រស់នៅក្នុងពន្ធនាគារមួយចំនួននៅកម្ពុជា

របាយការណ៍សង្ខេបលីកាដូ
ខែមិថុនា ២០១០


សម្ព័ន្ធខ្មែរជំរឿនិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# គម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ

## ការពិនិត្យឡើងវិញនូវស្ថានភាពរស់នៅរបស់ម្តាយ ស្ត្រីមានផ្ទៃពោះ និងកុមារតូចៗ រស់នៅក្នុងពន្ធនាគារមួយចំនួននៅកម្ពុជា

---

របាយការណ៍សង្ខេប

ខែមិថុនា ឆ្នាំ២០១០


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរព សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូ អនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំ២ពីរ :**

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្ដល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្ដល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្ដល់ជូនដោយក្រុមអ្នកប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវិជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្ដល់សេវាវិជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន ១២ កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្ដល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**ទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណៈជនអំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្ដាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្ដូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេត ដោយលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

## ចំពោះព័ត៌មានបន្ថែមសូមទាក់ទង៖

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ

អាសយដ្ឋាន៖ អង្គការលីកាដូ ( សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស )

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥) ២៣ ៧២៧ ១០២ / ៣៦៤ ៩០១   ទូរសារ៖ (៨៥៥) ២៣ ៧២៧ ១០២ / ២១៧ ៦២៦

អ៊ីម៉ែល៖ contact@licadho-cambodia.org   គេហទំព័រ៖ http://www.licadho-cambodia.org/

# មាតិកា


សេចក្តីសង្ខេប ~~~~~~~~ I

១. សេចក្តីផ្តើម ~~~~~~~~ ១

សវនា -------- ១

២. វិធីសាស្ត្រស្រាវជ្រាវ ~~~~~~~~ ២

ការសម្ភាសន៍ -------- ២

ដែនកំណត់នៃការសម្ភាសន៍ -------- ៣

៣. ព័ត៌មានទូទៅស្តីពីកុមារតូចៗនៅជាមួយម្តាយក្នុងពន្ធនាគារ ~~~~~~~~ ៤

៤. ការនៅក្នុងពន្ធនាគារ ~~~~~~~~ ៥

ស្ថានភាពបន្ទប់ឃុំឃាំង -------- ៥

ម្ហូបអាហារ និង ទឹក -------- ៦

សម្លៀកបំពាក់ -------- ៨

សុខភាព និង ការថែទាំ -------- ៩

ការជួបគ្រួសារ -------- ១១

ពេលវេលាចេញក្រៅបន្ទប់ឃុំឃាំង -------- ១១

ការអប់រំ -------- ១២

ការលេងកំសាន្ត -------- ១៤

ការរំលោភបំពាន -------- ១៦

៥. ទិសដៅអនាគត ~~~~~~~~ ១៧

បញ្ហាសំខាន់ៗ -------- ១៧

ការពង្រីកគម្រោងផ្តល់ជំនួយដល់កុមាររស់នៅក្នុងពន្ធនាជាមួយម្តាយ -------- ១៨

*កែលំអរសេវាកម្មដែលមានស្រាប់* -------- ១៨

*ការរៀបចំកម្មវិធីសិក្សា* -------- ១៨

*ការបញ្ជូលកុមារជាកូនៗរបស់ឆ្មាំពន្ធនាគារ* -------- ២១

៦. របាយការណ៍ពន្ធនាគារនីមួយៗ ~~~~~~~~ ២២

៧. ការផ្តល់អនុសាសន៍ ~~~~~~~~ ២៨

# សេចក្ដីសង្ខេប

នៅខែមិថុនា ឆ្នាំ២០០៩ អង្គការលីកាដូ សហការជាមួយអង្គការ ហូរីហ្សិន (Horizons) បានចាប់ផ្ដើមធ្វើការសិក្សាស្រាវជ្រាវថ្នាក់ជាតិមួយស្ដីពីស្ត្រីមានកូនតូចៗរស់នៅក្នុងពន្ធនាគារ។ គោលបំណងនៃការសិក្សានេះគឺដើម្បីកំណត់នូវបញ្ហាសំខាន់ៗដែលស្ត្រី និងកុមារទាំងនោះកំពុងប្រឈមមុខ ខណៈពេលពួកគេជាប់ឃុំឃាំងក្នុងពន្ធនាគារជាពិសេស បញ្ហាម្ហូបអាហារ សម្លៀកបំពាក់ សុខភាព និងអនាម័យ។ វិសាលភាព ដែលគម្រោងផ្ដល់ជំនួយកុមាររស់នៅជាមួយម្ដាយក្នុងពន្ធនាគារបានធ្វើការដោះស្រាយនូវបញ្ហាទាំងនេះ និងពិនិត្យមើលនូវតម្រូវការសម្រាប់កម្មវិធីអប់រំ និងការកំសាន្តសម្រាប់កុមាររស់នៅក្នុងពន្ធនាគារ។

នៅខែកញ្ញា ឆ្នាំ២០០៩ មានស្ត្រីមានផ្ទៃពោះ ៦ នាក់ និងម្ដាយដែលមានកូនតូចៗរស់នៅជាមួយ ៣៧ នាក់ ដែលមានកុមារតូចៗសរុប ៤០ នាក់ នៅក្នុងពន្ធនាគារកម្ពុជាចំនួន ១០ ដែលនៅភ្នំពេញ និងទីក្រុង ៩ ទៀតតាមបណ្ដាខេត្ត។ ជីវិតនៅក្នុងពន្ធនាគារកម្ពុជា គឺជាជីវិតមួយដែលពោរពេញទៅដោយភាពគ្រោតគ្រាតយ៉ាងខ្លាំងសម្រាប់មនុស្សគ្រប់រូប ហើយជាពិសេស និងកាន់តែគ្រោតគ្រាតថែមទៀតនោះគឺ ជីវិតរបស់កុមារតូចៗដែលកើតនៅក្នុង ឬ តាមម្ដាយមករស់នៅទីនោះ ក្រោយពីអស់ជម្រើសក្នុងការរកកន្លែងផ្សេងដើម្បីរស់នៅទៅហើយ។ កុមារទាំងនោះ ត្រូវបានដាក់ឱ្យរស់នៅក្នុងបន្ទប់តូចចង្អៀត ព្រមជាមួយនឹងការទទួលបាននូវម្ហូបអាហារ ទឹក ការថែទាំសុខភាព ការអប់រំ និងការលេងកំសាន្តដ៏តិចតួចជាទីបំផុត។ កុមារទាំងនោះ ត្រូវបានឃុំឃាំងនៅក្នុងស្ថានភាពមួយដែលទទួលផលប៉ះពាល់ដល់សុខភាពរាងកាយ ផ្លូវចិត្ត និងសុខមាលភាពអារម្មណ៍យ៉ាងខ្លាំង ។

ទោះបីជាកុមារត្រូវបានច្បាប់អនុញ្ញាតឱ្យនៅជាមួយម្ដាយក្នុងពន្ធនាគារដល់អាយុ ៦ ឆ្នាំ ក៏ដោយ ក៏យើងសង្កេតឃើញថា មានកុមារមួយចំនួនបានបន្តស្នាក់នៅជាមួយម្ដាយរហូតដល់អាយុ ៨ ឆ្នាំដែរ ។ កុមារទាំងនោះត្រូវតែបន្តស្នាក់នៅដោយសារតែពួកគេពុំដឹងទៅរស់នៅទីណា។ ដូច្នេះទោះបីជារាជរដ្ឋាភិបាលអនុញ្ញាតឱ្យកូនតូចៗស្នាក់នៅជាមួយម្ដាយក្នុងពន្ធនាគារក៏ដោយ ក៏ត្រូវតែផ្ដល់ការផ្គត់ផ្គង់ក្នុងកំរិតណាមួយឱ្យពួកគេបានរស់នៅសមរម្យផង ។

## សេចក្ដីថ្លែងអំណរគុណ

**លីកាដូ** សូមថ្លែងអំណរគុណដល់ An Samon, Bree Fitzgeralt, Camilla Jordanwood និង Sky Rose ចំពោះការចូលរួមចំណែកនៅក្នុងការបោះពុម្ពផ្សាយនូវរបាយការណ៍នេះ។

# ១. សេចក្តីផ្តើម

## សវតា

នៅឆ្នាំ២០០២ លីកាដូ បានចេញផ្សាយរបាយការណ៍មួយដែលមានចំណងជើងថា "អ្នកគ្មានទោសនៅក្នុងពន្ធនាគារៈ ជារបាយការណ៍ស្តីពីសិទ្ធិរបស់កុមារដែលធំដឹងក្តីនៅក្នុងពន្ធនាគារ" ដោយបានរកឃើញថាកុមារតូចៗដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយ និងស្ត្រីមានផ្ទៃពោះពុំបានទទួលនូវការថែទាំសុខភាពឱ្យបានសមរម្យ ខ្វះខាតម្ហូបអាហារ ការអប់រំ និងសិទ្ធិមនុស្សជាមូលដ្ឋានជាដើម។ នៅឆ្នាំ២០០៣ លីកាដូ បានបង្កើតគម្រោងមួយមានឈ្មោះថា "គម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ" ដែលមានគោលបំណងដើម្បីផ្តល់អាហារបន្ថែម សម្លៀកបំពាក់ និងការថែទាំសុខភាពជាមូលដ្ឋានដល់កុមារតូចៗ និងស្ត្រីមានផ្ទៃពោះក្នុងពន្ធនាគារទាំងនោះ តាមរយៈការបង្កើតដៃគូរវាងអង្គការ និងពន្ធនាគារមួយចំនួន។ បន្ទាប់ពីការបង្កើតគម្រោងនេះហើយ លីកាដូបានរកឃើញថា នៅមានកង្វះខាតមួយចំនួនទៀតដែលត្រូវជួយដល់កុមារតូចៗ និងម្តាយរបស់ពួកគេ ដូចជា ការទទួលបានការអប់រំ និងការលេងកំសាន្តជាដើម ។



*ស្ត្រី និងកុមារនៅមណ្ឌលអប់រំកែប្រែទី ២ នាទិវាសិទ្ធិស្ត្រីអន្តរជាតិ*

## គោលបំណងៈ

- ផ្តល់នូវទិដ្ឋភាពទូទៅថ្នាក់ជាតិស្តីពីជីវិតនៅក្នុងពន្ធនាគារ និងកំណត់បង្ហាញនូវបញ្ហាសំខាន់ៗដែលកុមារ ម្តាយ និងស្ត្រីមានផ្ទៃពោះទាំងនោះកំពុងប្រឈមខណៈជាប់ឃុំឃាំងក្នុងពន្ធនាគារ ។
- ពិចារណាអំពីវិសាលភាពដែលគម្រោងបានជួយឧបត្ថម្ភដើម្បីឆ្លើយតបទៅនឹងតម្រូវការនានា ដូចជា ម្ហូបអាហារ ទឹកស្អាត សម្លៀកបំពាក់ ការថែទាំសុខភាពជាមូលដ្ឋានព្រមទាំងរិះរកនូវវិធី ដើម្បីកែលំអរសេវាកម្មនេះឱ្យកាន់តែប្រសើរឡើងនាពេលអនាគត និង
- ពិចារណាអំពីវិធីដើម្បីពង្រីកគម្រោងឱ្យឆ្លើយតបនឹងតម្រូវការអប់រំ និងការលេងកំសាន្តរបស់កុមារតូចៗ និងស្ត្រីជាប់ឃុំឃាំងទាំងនោះ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើង ដើម្បីធ្វើការវាយតម្លៃនូវប្រសិទ្ធិភាពរបស់គម្រោងនេះ (បញ្ហាចម្បង គឺពាក់ព័ន្ធទៅនឹងការរស់នៅរបស់ស្ត្រីក្នុងពន្ធនាគារ) និងរៀបចំកម្មវិធីនេះសារឡើងវិញដែលជាការឆ្លើយតបទៅនឹងតម្រូវការអប់រំ និងការលេងកំសាន្តរបស់ស្ត្រី និងកុមារតូចៗទាំងនោះ។

### ការសម្ភាសន៍

សមាជិកក្រុមស្រាវជ្រាវបានសម្ភាសន៍ខ្លីៗជាមួយស្ត្រីមានផ្ទៃពោះចំនួន ៦ នាក់ និងម្តាយដែលមានកូនរស់នៅជាមួយក្នុងពន្ធនាគារចំនួន ៣២ នាក់ ក្នុងចំណោមស្ត្រី ៣៧ នាក់ ដែលកំពុងរស់នៅក្នុងពន្ធនាគារកម្ពុជានាពេលបច្ចុប្បន្ននេះ (នៅភ្នំពេញ និងក្រុងនានាតាមបណ្តា ខេត្តចំនួន ៩)។ ម្តាយចំនួន ៥ នាក់ពុំអនុញ្ញាតឱ្យក្រុមការងារសម្ភាសន៍ទេ។ ដូច្នេះ ជាលទ្ធផលមានតែកុមារ ៣៤ នាក់ប៉ុណ្ណោះក្នុងចំណោមកុមារទាំងអស់ ៤០ នាក់រស់នៅក្នុងពន្ធនាគារកម្ពុជាដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ។ ការសម្ភាសន៍ត្រូវបានធ្វើនៅក្នុងពន្ធនាគារដោយមានមានការត្រួតពិនិត្យពីសំណាក់ឆ្មាំពន្ធនាគារ។

ក្រុមការងារស្រាវជ្រាវមិនបានសម្ភាសន៍កុមារតូចៗទេ ដោយកុមារ ២៨ នាក់ ក្នុងចំណោមទាំង ៣៤ នាក់នោះមានអាយុតិចជាង ៥ ឆ្នាំ ហើយភាគច្រើនមិនទាន់ចេះនិយាយ ឬ អាចនិយាយបានតិចតួចពេក។ ដោយបារម្ភបញ្ហានានារបស់កុមារទាំងនោះ ដែលត្រូវធ្វើការសិក្សាស្វែងយល់នៅក្នុងការស្រាវជ្រាវនេះ និងការព្រួយបារម្ភរបស់មនុស្សពេញវ័យនៅក្នុងពន្ធនាគារ លីកាដូបានសម្ភាសន៍ជាមួយម្តាយជំនួសកូនៗរបស់ពួកគាត់វិញ។

ក្រុមការងារក៏បានសម្ភាសន៍ជាមួយប្រធាន ឬ អនុប្រធានពន្ធនាគារ និងឆ្មាំពន្ធនាគារចំនួន ៣៥ នាក់នៅ



ក្នុងពន្ធនាគារចំនួន ១០ ដែលមានកុមារតូចៗរស់នៅ។ ក្រុមការងារក៏បានសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងកូនៗរបស់ឆ្នាំ ដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីអប់រំ និងលេងកំសាន្តរបស់គម្រោងផងដែរ។

## ដែនកំណត់នៃការសម្ភាសន៍

ការសម្ភាសន៍ជាមួយអ្នកទោសត្រូវបានធ្វើឡើងនៅក្នុងពន្ធនាគារដោយមានវត្តមានឆ្មាំពន្ធនាគារ ឬក៏អ្នកទោសផ្សេងៗទៀតផងដែរ។ នៅពេលដែលអ្នកស្រាវជ្រាវបានព្យាយាមរកកន្លែងសម្ភាសន៍ឱ្យឆ្ងាយពីការស្តាប់ឮរបស់ឆ្មាំ គឺជារឿងមិនអាចធ្វើទៅបានទាល់តែសោះ ហើយអ្នកទោសស្ត្រីទាំងនោះមិនហ៊ាននិយាយឱ្យអស់ពីចិត្តឡើយ។

# ៣. ព័ត៌មានទូទៅស្តីពីកុមារតូចៗនៅជាមួយម្តាយក្នុងពន្ធនាគារ

ក្នុងចំណោមស្ត្រីទាំង ៣៨ នាក់ ដែលបានចូលរួមផ្តល់សម្ភាសន៍មាន ១៩ នាក់ គឺជាទណ្ឌិត និង ១៩ នាក់ ទៀតជាពិរុទ្ធជន ។

ហើយក្នុងចំណោមកុមារតូចៗទាំង ៣៤ នាក់ ដែលរស់នៅក្នុងពន្ធនាគារជាមួយម្តាយមាន ១៤ នាក់មានអាយុក្រោម ២ ឆ្នាំ ១១ នាក់ មានអាយុ ២ ឬ ៣ ឆ្នាំ ហើយ ៩ នាក់មានអាយុចន្លោះពី ៤ ទៅ ១១ ឆ្នាំ ។

ចំនួននឹងអាយុរបស់កុមារក្នុងពន្ធនាគារ



# ៤. ការនៅក្នុងពន្ធនាគារ

## ស្ថានភាពបន្ទប់ឃុំឃាំង

ភាពចង្អៀតណែន និងពុំសូវមានខ្យល់ចេញចូលគ្រប់គ្រាន់នៅក្នុងបន្ទប់ឃុំឃាំងនីមួយៗជាកត្តាគួរឱ្យព្រួយបារម្ភបំផុតសម្រាប់កុមារតូចៗ និងស្ត្រីមានផ្ទៃពោះ ជាពិសេសនៅមណ្ឌលអប់រំកែប្រែទី២ និងពន្ធនាគារតាខ្មៅ។

មណ្ឌលអប់រំកែប្រែទី២ នៅភ្នំពេញគឺជាពន្ធនាគារមួយដែលមានអ្នកទោសច្រើនជាងគេបំផុតនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ ដោយអ្នកទោសស្ត្រីដែលមានកូនរស់នៅជាមួយចំនួន ៧ នាក់ ឃុំឃាំងជាមួយស្ត្រីជាង ៤០ នាក់ទៀត។ នៅពន្ធនាគារតាខ្មៅ ក៏មានអ្នកទោសជាច្រើននាក់ដែរនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ ដោយអ្នកទោសស្ត្រីមានកូនរស់នៅជាមួយទាំងអស់ត្រូវបានឃុំឃាំងជាមួយអ្នកទោសស្ត្រី ២៥នាក់ផ្សេងទៀត។ ចំណែកនៅពន្ធនាគារខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង កុមារតូចៗ ម្តាយ និងស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវបានឃុំឃាំងជាមួយគ្នានៅក្នុងបន្ទប់ឃុំឃាំងជាច្រើនដែលក្នុងបន្ទប់ឃុំឃាំងនីមួយៗមានពី ១០ ទៅ ២០ នាក់។ នៅពន្ធនាគារផ្សេងៗទៀត ម្តាយ និងកូនៗត្រូវបានឃុំឃាំងនៅក្នុងបន្ទប់ដែលមានមនុស្សតិចជាង ១០ នាក់។

របាយការណ៍ស្តីពីភាពចង្អៀតណែនខ្លាំង ការខ្វះខ្យល់ដកដង្ហើមក្តៅខ្លាំង និងការពុលដោយផ្សែងបារីបានធ្វើឱ្យអ្នកទោសជាច្រើន (ដូចជាកុមារតូចៗ ស្ត្រីមានផ្ទៃពោះ និងទារកមិនទាន់កើត) រងគ្រោះថ្នាក់ដល់សុខភាពយ៉ាងខ្លាំងជាពិសេសជម្ងឺរបេង។ របេង គឺជាជម្ងឺមួយប្រភេទដែលឆ្លងតាមរយៈការដកដង្ហើម ដូច្នេះហើយអ្នកណាដែលនៅជិតៗអ្នកជម្ងឺក្នុងរយៈពេលយូរ ញឹកញាប់ ឬ រស់នៅក្នុងកន្លែងតូចចង្អៀតជាមួយអ្នកជម្ងឺក្នុងបរិយាកាសខ្វះខ្យល់អាកាស អ្នកទាំងនោះសុទ្ធតែងាយឆ្លងជម្ងឺរបេងនេះជាទីបំផុត។

ទោះបីជាអ្នកទោសដែលមានរោគសញ្ញាជម្ងឺរបេង ត្រូវបានដាក់នៅក្នុងបន្ទប់ឃុំឃាំងដាច់ដោយឡែកនៅឆ្ងាយពីអ្នកទោសភាគច្រើនក៏ដោយ ក៏គ្រោះថ្នាក់នៃការឆ្លងមេរោគនេះនៅតែមានអត្រាខ្ពស់ដែរ ដោយបន្ទប់ដែលត្រូវដាក់អ្នកកើតរបេងនោះនៅមិនឆ្ងាយពីបន្ទប់អ្នកទោសផ្សេងទៀត ព្រមទាំងពុំសូវមានខ្យល់អាកាសគ្រប់គ្រាន់ទៀតផង។ នៅមណ្ឌលអប់រំកែប្រែទី២ ស្ត្រី និងកុមារត្រូវបានដាក់នៅក្នុងបន្ទប់មួយដែលនៅជាប់បន្ទប់អ្នកទោសមានជម្ងឺរបេង។ ទោះបីជាមានការដាក់នៅដាច់ពីគ្នាក៏ដោយ ក៏អ្នកទោសដែលមានជម្ងឺរបេងទាំងនោះនៅតែត្រូវបានអនុញ្ញាតឱ្យធ្វើការប្រាស្រ័យទាក់ទងគ្នាជាប្រចាំជាមួយស្ត្រី និងកុមារដែលនៅបន្ទប់ជាប់គ្នានោះដែរ ហើយដោយសារតែបញ្ហានេះ ស្ត្រីមួយចំនួនបានបញ្ជូនកូនរបស់ខ្លួនចេញឱ្យទៅរស់នៅមួយមិត្តភ័ក្ត ឬ សាច់ញាតិក្រៅពន្ធនាគារ។ ម្តាយភាគច្រើនបាននិយាយថា ជារឿយៗកូនៗរបស់ពួកគេតែងតែក្តៅខ្លួន និងបែកញើសនៅពេលយប់អាស្រ័យ ដោយសីតុណ្ហភាពក្តៅខ្លាំងនៅក្នុងបន្ទប់ ហើយទោះបីជាឈឺធ្ងន់យ៉ាងណាក៏ដោយ ក៏មិនអាច

ទទួលបានការព្យាបាលភ្លាមៗក្នុងពេលយប់នោះដែរ គឺត្រូវរងចាំរហូតដល់ព្រឹកថ្ងៃបន្ទាប់។

ការទទួលបាននូវការថែទាំសុខភាពសមរម្យអាចជួយកាត់បន្ថយការឆ្លងជម្ងឺ និងមេរោគផ្សេងៗ។




## ម្ហូបអាហារ និង ទឹក

រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នបានផ្តល់ថវិកាចំនួន ២,៨០០ រៀលសម្រាប់អ្នកទោសម្នាក់ក្នុង ១ថ្ងៃចំណែកកូនតាមម្តាយទទួលបានពាក់កណ្តាលនៃរបបម្តាយ ១,៤០០ រៀលក្នុង ១ ថ្ងៃ ចាប់ពីឆ្នាំ២០០៩ មក ដែលកាលពីមុនត្រឹមតែ ១,៥០០ រៀលប៉ុណ្ណោះ សម្រាប់អ្នកទោសម្នាក់ និងកូនតាមម្តាយពុំបានទទួលឡើយ។ ថវិកា ២,៨០០ រៀលនេះ គឺសម្រាប់ចំណាយទៅលើម្ហូបអាហារ ទឹក អគ្គិសនី សម្លៀកបំពាក់ និងការចំណាយផ្សេងៗទាំងអស់។ បច្ចុប្បន្ននេះស្ត្រីមានផ្ទៃពោះ និងកុមាររស់នៅក្នុងពន្ធនាគារ នៅតែពុំទាន់បានទទួលជំនួយឧបត្ថម្ភបន្ថែមលើម្ហូបអាហារ ទឹក ឬថ្នាំពេទ្យគ្រប់គ្រាន់នៅឡើយ។ ទោះបីជាអាជ្ញាធរពន្ធនាគារមានករណីកិច្ចក្នុងការផ្តល់ម្ហូបអាហារ និងការថែទាំសុខភាពដល់ម្តាយ និងកូនៗនៅក្នុងពន្ធនាគារ[១] ក៏ដោយក៏ស្ត្រីជាម្តាយទាំងឡាយនៅតែជួបប្រទះនូវការលំបាក។ នៅក្នុងកិច្ចសម្ភាសន៍អ្នកទោសស្ត្រីមួយចំនួនបានលើកឡើងថា រាជរដ្ឋាភិបាលបានសន្យាផ្តល់របបអាហារប្រចាំថ្ងៃថ្មី ហើយបញ្ហានេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដោយប្រធានពន្ធនាគារដោយបានពន្យល់ថា គេសង្ឃឹមថានឹងបានទទួលប្រាក់ឧបត្ថម្ភ ១,៣០០ រៀល បន្ថែមទៀតសម្រាប់មនុស្សពេញវ័យ និង ១,៤០០រៀល

[១] មាត្រា ១៨ ខ នៃប្រកាសលេខ ២១៧ របស់ក្រសួងមហាផ្ទៃចេញថ្ងៃទី ៣០ មិនា ១៩៩៨

សម្រាប់កុមារ។ ការផ្តល់ប្រាក់របបបន្ថែមនេះ មិនទាន់ធ្លាក់មកនៅឡើយទេហើយក៏មិនទាន់ច្បាស់ថា ពេលណានឹងទទួលបានដែរ។

### ***កង្វះខាតម្ហូបអាហារ និង ទឹក***

*"នៅពេលដែលកូនប្រុសរបស់ខ្ញុំ វាហេវ វាទាររកបាយ ហើយពេលដែលខ្ញុំគ្មានបាយឱ្យ វាកាន់ចានដើរសុំបាយគេ"*។ សម្តីរបស់ស្ត្រីជាម្តាយម្នាក់នៅមណ្ឌលអប់រំកែប្រែទី២។

*"ខ្ញុំពុំសូវមានទឹកដោះគ្រប់គ្រាន់ឱ្យកូនខ្ញុំបៅទេ ដូច្នេះខ្ញុំយកទឹកស្ករបញ្ចុកវា ដែលធ្វើឱ្យវាមានជម្ងឺរាគ"*។ សម្តីរបស់ស្ត្រីជាមួយនៅពន្ធនាគារខេត្តកំពង់ចាម។

ទោះបីជាម្តាយ និងកូន៧បច្ចុប្បន្នបានទទួល ម្ហូបអាហារ និងទឹកបន្ថែមតាមរយៈគម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ ដែលជាការបន្ថែមពីលើរបបអាហារដែលទទួលបានពីពន្ធនាគារក៏ដោយក៏ស្ត្រីចំនួន ៦៦% និងកុមារ ៦៣%ដែលបានផ្តល់ការសម្ភាសន៍បាននិយាយថា ពួកគេនៅមិនទាន់ទទួលបានម្ហូបអាហារហូបចុកគ្រប់គ្រាន់នៅឡើយដែរ។ អាស្រ័យដោយទឹកដោះមិនគ្រប់គ្រាន់ ស្ត្រីមួយចំនួនបានប្រើប្រាស់ទឹកស្ករ ទឹកមិនបានច្រោះ និងបាយធ្វើជាអាហារបន្ថែមពីលើទឹកដោះម្តាយ។ កុមារធំៗដែលពុំមានអាហារហូបចុកគ្រប់គ្រាន់តែងតែយំ និងសុំបាយគេហូប ឬ ដើររើសម្ហូបអាហារដែលគេបោះចោលក្នុងធុងសម្រាម។

អ្នកទោសត្រូវបានអនុញ្ញាតឱ្យទទួលម្ហូបអាហារបន្ថែមពីសាច់ញាតិរបស់ខ្លួន ប៉ុន្តែតាមការស្រាវជ្រាវបានឱ្យដឹងថា មានតែស្ត្រី ៣៥%ប៉ុណ្ណោះក្នុងចំណោមអ្នកផ្តល់សម្ភាសន៍បានទទួលម្ហូបអាហារបន្ថែមពីបងប្អូនសាច់ញាតិ ហើយមានស្ត្រីជាច្រើនបាននិយាយថា ដើម្បីយកម្ហូបអាហារចូលមកបានលុះត្រាតែបង់លុយឱ្យឆ្មាំ និងខ្លះទៀតនិយាយថា ទោះបីមានការឧបត្ថម្ភពីគ្រួសារក៏នៅតែខ្វះខាតដែរ។ ស្ត្រីជាម្តាយមួយចំនួនទទួលបានការឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលនានាដូចជា NAAA អង្គការកុមារមេត្តា និងស្ថានទូតម៉ាល់តាជាដើម។ ប៉ុន្តែស្ត្រីមួយចំនួនត្រូវបានឃុំឃាំងយ៉ាងឆ្ងាយពីគ្រួសាររបស់ខ្លួន ដូច្នេះពុំដែលបានទទួលការឧបត្ថម្ភពីគ្រួសារទាល់តែសោះ ក៏ដូចជាគ្មានឋិកាសសម្រាប់ទិញទំនិញពីឆ្មាំពន្ធនាគារដែលទាំងនេះ គឺជាកត្តាដែលពួកគេមិនអាចទទួលបានអាហារបន្ថែម។

បរិមាណ និងគុណភាពម្ហូបអាហារដែលស្ត្រីជាម្តាយទទួលបានមានភាពខុសគ្នាយ៉ាងខ្លាំងពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត និងអាស្រ័យទៅលើការជួយឧបត្ថម្ភមួយភាគធំពីខាងក្រៅដែលមានភាពខុសគ្នាពីមនុស្សម្នាក់ទៅម្នាក់ទៀត។ ឧទាហរណ៍ នៅពន្ធនាគារខេត្តបាត់ដំបង អ្នកទោសពីរនាក់បានផ្តល់ព័ត៌មានខុសគ្នាយ៉ាងខ្លាំងអំពីម្ហូបអាហារ។ ម្នាក់ដំបូងនិយាយថា គាត់ហូបបាយសម្លដែលមានត្រី និងបន្លែ ហើយពុំមានការត្អូញត្អែរអំពីម្ហូបអាហារទេ។ ចំណែកឯស្ត្រីម្នាក់ទៀតនៅក្នុងពន្ធនាគារជាមួយគ្នានេះបានរៀបរាប់ថា រាល់ពេលគាត់មានតែបាយជាមួយសម្លដែលមានតែបន្លែ ព្រមទាំងបញ្ជាក់ថា ម្ហូបអាហារទាំងនោះធ្វើមិនស្អាតទេ ហើយថែមទាំងចំអិន

មិនបានឆ្អិនល្អថែមទៀត។ ភាពខុសគ្នារវាងស្ត្រីទាំងពីរនាក់ ប្រហែលជាបណ្ដាលមកពីការទទួលបាននូវអាហារពីខាងក្រៅដោយស្ត្រីទី១ និយាយថា គាត់ទទួលបានរបបអាហារពីអង្គការ និងសាច់ញាតិមកសួរសុខទុក្ខគាត់ ហើយស្ត្រីទី២ មិនបាននិយាយអំពីការទទួលបានម្ហូបអាហារបន្ថែមពីក្រុមគ្រួសារឡើយ។

បន្ទាប់ពីការបង្កើតនូវមជ្ឈមណ្ឌលថែទាំកុមារនៅមណ្ឌលអប់រំកែប្រែទី២ របបអាហារសម្រាប់កុមារត្រូវបានកាត់បន្ថយអស់៥០%ទៅមជ្ឈមណ្ឌលនេះ។ គេបាននិយាយថា ស្ថានទូតម៉ាល់តាធ្លាប់បានផ្ដល់ម្ហូបអាហារដោយផ្ទាល់ដល់ម្ដាយហើយបានប្រាប់ម្ដាយថា កុមារនៅឯមជ្ឈមណ្ឌលថែទាំកុមារទទួលបានរបបអាហារបីពេលក្នុង១ថ្ងៃ ប៉ុន្តែជាក់ស្ដែងកុមារទាំងនោះទទួលបានតែពីរពេលប៉ុណ្ណោះក្នុង១ថ្ងៃ។

### *បរិមាណសារធាតុចិញ្ចឹមនៃអាហារ*

យោងតាមការសម្ភាសន៍ស្ត្រីជាម្ដាយទាំងឡាយ បានបង្ហាញនូវការព្រួយបារម្ភអំពីគុណភាព និងបរិមាណសារធាតុចិញ្ចឹមនៃម្ហូបអាហារដែលពន្ធនាគារបានផ្ដល់ឱ្យមានកម្រិតទាប ដែលជាកត្តានាំឱ្យប៉ះពាល់ដល់សុខភាពព្រមទាំងមិនអាចធ្វើឱ្យកូនៗរបស់ពួកគេមានការលូតលាស់បានពេញលេញ។ មានអ្នកខ្លះនិយាយថា ចុងភៅភាគច្រើនតែងលាងសំអាតបន្លែ ត្រី សាច់មិនសូវស្អាត ដែលស្ទើរតែមិនអាចហូបបាន ហើយឯបាយវិញជួនកាលខ្លោចជួនកាលឆៅក៏មានដែរ ពេលខ្លះសម្លមានក្លិនស្អុយ។ អ្នកខ្លះនិយាយថា ម្ហូបអាហារបែបនេះ ហើយដែលបណ្ដាលឱ្យកូនៗរបស់ពួកគេឈឺ ដោយពួកគេតែងតែរាគ និងកើតមានជម្ងឺគ្រុនក្ដៅ។

នៅពន្ធនាគារខ្លះ បានទទួលការឧបត្ថម្ភបន្ថែមជាត្រី និងអង្ករ ហើយពន្ធនាគារខ្លះទៀតបានទទួលការឧបត្ថម្ភតែអង្ករប៉ុណ្ណោះ និងទឹកដោះគោសម្រាប់កុមារតូចៗ។ ម្ដាយមួយចំនួនបានលើកឡើងថា របបអាហារដែលពួកគាត់ទទួលពីអ្នកម្ចាស់ជំនួយពុំបានផ្ដល់នូវសារធាតុចិញ្ចឹម ដែលពួកគេត្រូវការសម្រាប់ការលូតលាស់សុខភាពទេ ពីព្រោះថាខ្វះបន្លែ និងសាច់ស្រស់ដែលជាប្រភពនៃជាតិដែក និងប្រូតេអ៊ីន។

### *លទ្ធភាពនៃការទទួលបានទឹកស្អាត*

ស្ត្រី និងកុមារមួយចំនួនធំពុំបានទទួលទឹកចម្រោះស្អាតសម្រាប់ផឹកទេ។ ពន្ធនាគារមួយចំនួនពុំមានបណ្ដាញទឹកស្អាតទៅដល់ទេ ហើយពួកគេពឹងផ្អែកមួយភាគធំលើទឹកអណ្ដូង ឬ ទឹកភ្លៀងត្រងទុកដាក់ក្នុងធុង។ ទឹកភ្លៀងដែលរក្សាទុកនៅក្នុងធុងច្រើនតែប្រើប្រាស់មិនគ្រប់គ្រាន់ទេ។ ប្រធានពន្ធនាគារខេត្តកោះកុងបានលើកឡើងថា ប្រសិនបើមានធុងទឹកធំៗច្រើនសម្រាប់រក្សាទឹកទុក នោះអាចដោះស្រាយបញ្ហាបាន ។

## សម្លៀកបំពាក់

ទោះបីជាម្ចាស់ជំនួយបានផ្ដល់សម្លៀកបំពាក់ដល់ស្ត្រី និងកុមារក៏ដោយក៏ស្ត្រីជាម្ដាយភាគច្រើនលើកឡើង

ថា កូនៗរបស់ពួកគេមិនទាន់មានសម្លៀកបំពាក់ និងរបស់របរសម្រាប់លេងឱ្យគ្រប់គ្រាន់នៅឡើយទេ។

## សុខភាព និង ការផ្ចិតផ្ចង់

### *ការឈឺជាញឹកញាប់*

យោងតាមការសម្ភាសន៍ជាមួយស្ត្រី និងឆ្មាំពន្ធនាគារបានឱ្យដឹងថា កុមារតែងតែឈឺជាញឹកញាប់កើតជម្ងឺឆ្លង និងជម្ងឺប្រភេទផ្សេងៗ។ ជាទូទៅជម្ងឺដែលតែងតែកើតញឹកញាប់ជាងគេគឺ គ្រុនក្តៅ រាគ ជម្ងឺផ្លូវដង្ហើម ជម្ងឺសើរស្បែក ឬ កមរមាស់ ថៃ និងរបេងជាដើម។ តាមសម្តីស្ត្រីដែលបានសម្ភាសន៍បានលើកឡើង ថាបញ្ហាទាំងគឺបណ្តាលមកពីកង្វះម្ហូបអាហារ និងទឹកស្អាតសម្រាប់ផឹក កង្វះការថែទាំងសុខភាព និងអនាម័យ។ ការមិនបានព្យាបាលជម្ងឺនានាក្នុងស្ថានភាពបែបនេះ នឹងអាចបណ្តាលឱ្យមានការឆ្លងរាលដាលយ៉ាងឆាប់រហ័ស (ជាពិសេសសម្រាប់កុមារតូចៗ) និងជាកត្តាមួយបណ្តាលឱ្យមានកំណើននូវមរណៈកុមារនៅកម្ពុជា[២]។ កង្វះការថែទាំសុខភាពគ្រប់គ្រាន់ ជម្ងឺ និងមេរោគនានាអាចឆ្លងទៅមនុស្សទាំងឡាយដែលនៅជិតៗនោះបានយ៉ាងងាយ ហេតុនេះ ស្ត្រី និង កុមារអាចប្រឈមគ្រោះថ្នាក់ខ្លាំងជាទីបំផុត។

### *ការទទួលសេវាសុខភាព*

> *"យើងចង់ឱ្យមានមណ្ឌលថែទាំសុខភាព ដើម្បីងាយស្រួលក្នុងការពិគ្រោះយោបល់ជាមួយគ្រូពេទ្យ និងទទួលបានថ្នាំពេទ្យគ្រប់គ្រាន់ ពេលណាកូនៗរបស់យើងឈឺ។"* សម្តីរបស់ស្ត្រីជាម្តាយនៅពន្ធនាគារខេត្តកំពង់ឆ្នាំង។

ទោះបីជាមានការផ្តល់ជំនួយផ្នែកសុខាភិបាលខ្លះៗតាមរយៈអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក៏ដោយក៏ស្ត្រី និងកុមារនៅក្នុងពន្ធនាគារមិនទាន់បានទទួលបានការព្យាបាលគ្រប់គ្រាន់ និងទាន់ពេលវេលានៅឡើយដែរនៅពេលដែលពួកគាត់ឈឺឬមានជម្ងឺ។ យោងតាមប្រធានពន្ធនាគារមួយចំនួនពន្ធនាគារខ្លះ ពុំមានថ្នាំរក្សាទុកបានគ្រប់គ្រាន់ទេ ហើយនៅពេលអ្នកណាត្រូវការជួបគ្រូពេទ្យម្តងៗស្ទើរមិនអាចចូលជួបបានផង។ ការព្យាបាលនៅពេលយប់គឺជួបបញ្ហាលំបាកច្រើនណាស់ជាពិសេសចំពោះស្ត្រី និងកុមារដែលត្រូវរងចាំរហូតដល់ថ្ងៃស្អែក។ ប្រសិនបើកុមារមានជម្ងឺធ្ងន់ធ្ងរ នោះគេត្រូវបញ្ជូនទៅមន្ទីរពេទ្យខេត្តជាមួយម្តាយដោយមានកិច្ចការពារយ៉ាងដិតដល់ដោយឆ្មាំ ដែលនេះជាបញ្ហាមួយដោយមិនអាចរៀបចំបានក្នុងរយៈខ្លីឡើយ។ បើពុំមានថវិកាដើម្បីទិញថ្នាំពីឆ្មាំពន្ធនាគារទេ ស្ត្រី និងកុមារមួយចំនួនត្រូវរងចាំរហូតដល់ថ្ងៃណាមួយគ្រូពេទ្យមានថ្នាំ ឬ មានលទ្ធភាពចំណាយ

[២] ក្នុងចំណោមកុមារស្លាប់ ១០៦ នាក់ ក្រសួងសុខាភិបាលបានប៉ាន់ស្មានថា ៣១.១% គឺបណ្តាលមកពីជម្ងឺរាគ ហើយ ៤១.៥% បណ្តាលមកពីបណ្តាលមកពីជម្ងឺក្អក ៦៦% បណ្តាលមកពីគ្រុនក្តៅ : វិទ្យាស្ថានជាតិសុខភាពសាធារណៈ វិទ្យាជាតិស្ថានស្ថិតិ (កម្ពុជា) និង ORO Macro ។ ការសិក្សាស្រាវជ្រាវអំពីប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០៥ និង ២០០៦ ទំព័រ ១៣៣។

លើសេវាកម្មសុខាភិបាលណាមួយដែលចាំបាច់នោះ ។

## ការថែទាំសុខភាពមុន និង ក្រោយពេលសម្រាលកូន

*"ខ្ញុំចង់ឱ្យមានកម្មវិធីពិសេសមួយសម្រាប់ស្ត្រីមានផ្ទៃពោះ ដើម្បីឱ្យយើងងាយយល់អំពីរបៀបថែរក្សាសុខភាពរបស់យើង នៅពេលមានផ្ទៃពោះរបៀបសម្រាលកូន របៀបបំបៅដោះកូន និងរបៀបប្រើប្រាស់ថ្នាំឱ្យបានត្រឹមត្រូវ"* ។
សម្ភីស្ត្រីជាម្តាយម្នាក់នៅមណ្ឌលអប់រំកែប្រែទី ២ ។

ពន្ធនាគារកម្ពុជាបច្ចុប្បន្ន ពុំបានផ្តល់ការថែទាំសុខភាពមុន និង ក្រោយពេលសម្រាលកូនដល់អ្នកទោសឱ្យបានគ្រប់គ្រាន់នៅឡើយទេ។ ស្ត្រីមានផ្ទៃពោះ ៥ នាក់ក្នុងចំណោម ៦នាក់នៅក្នុងពន្ធនាគារ ៣ផ្សេងគ្នាដែលបានផ្តល់សម្ភាសន៍ដល់ការស្រាវជ្រាវនេះបានអះអាងថា នៅមុនពេលក្នុងពេល និងក្រោយពេលសម្រាលកូន ពួកគេពុំបានទទួលការថែទាំសុខភាពបានគ្រាប់គ្រាន់ទេ ហើយទាំងអស់គ្នាសុទ្ធតែបានបង្ហាញនូវការខ្វាយខ្វល់ពាក់ព័ន្ធនឹងសុខភាពរបស់ពួកគេ។

ភាគច្រើនមិនត្រូវបានព្យាបាលដោយគ្រូពេទ្យ ឬបានទទួលការពិនិត្យផ្ទៃពោះនៅមុនពេលសម្រាលកូនទេ ដូច្នេះពួកគេក៏ពុំបានទទួលវីតាមីន ការចាក់ថ្នាំបង្ការ ឬ ថ្នាំពេទ្យចាំបាច់ដើម្បីធានានូវការលូតលាស់ប្រកបដោយសុខភាពបរិបូរណ៍របស់ទារកមិនទាន់កើតផងដែរ។

ទោះបីជាផែនការសម្រាលកូនត្រូវបានត្រៀមទុកនៅចុងនៃខែទី៧នៃការមានផ្ទៃពោះក៏ដោយ[៣] ប៉ុន្តែជាក់ស្តែងវាកម្រណាស់សំរាប់ឱ្យមានការពិនិត្យផ្ទៃពោះមុនពេលសំរាលនោះ។

ស្ត្រីផ្តល់សម្ភាសន៍មួយចំនួនបានឱ្យដឹងថា ពួកគេមិនសូវដឹង ឬ មិនដឹងសោះអំពីកាលបរិច្ឆេទនៃការសម្រាលកូនរបស់ខ្លួន។ ទោះបីជាអ្នកផ្តល់ព័ត៌មានសំខាន់ៗសុទ្ធតែជាមនុស្សធ្វើការនៅក្នុងពន្ធនាគារ ហើយបានអះអាងថា បច្ចុប្បន្ននេះកម្រមានស្ត្រីណាសម្រាលកូនក្នុងពន្ធនាគារណាស់ ដោយគេច្រើនតែបញ្ជូនទៅសម្រាលនៅមន្ទីរពេទ្យ ប៉ុន្តែក៏មានអ្នកទោសម្នាក់ដែលយើងបានសម្ភាសន៍បាននិយាយថានាងគិតថា នាងប្រហែលជាត្រូវសម្រាលកូននៅពន្ធនាគារ ។

ការសម្រាលកូនពេលយប់ គឺជាការបន្ថែមនូវភាពស្មុគស្មាញថែមទៀត ដោយហេតុថា ពុំមានផែនការរៀបចំទុកជាមុនដើម្បីសម្រាលកូននេះឡើយ។ ស្ត្រីមួយចំនួនបានបង្ហាញនូវការព្រួយបារម្ភថា ប្រសិនបើពួកគេសម្រាលកូននៅពេលយប់ នោះពួកគេមិនអាចទទួលបានការជំនួយផ្នែកវេជ្ជសាស្ត្រដល់ការសម្រាលកូនឡើយ។ ការសម្រាលកូនពេលយប់ ទោះបីជាមិនសូវញឹកញាប់ក៏ដោយ ប៉ុន្តែវាអាចកើនឡើងពេលណាមួយ។

---

[៣] សេចក្តីប្រកាស ២១៧ ភាគ ៣.១១

*"ប្រសិនបើខ្ញុំសម្រាលកូនក្នុងពន្ធនាគារ ខ្ញុំនឹងឯកកោរតែម្នាក់ឯងជាពិសេសពេលយប់ ។ ខ្ញុំបានលឺថា មានស្ត្រីម្នាក់សម្រាលកូនតែម្នាក់ឯង ហើយនាងរងចាំរហូតដល់ទារកនោះស្ទើរតែស្លូតទម្រាំឃើញគ្រូពេទ្យពន្ធនាគារមកដល់"។*
សម្តីស្ត្រីម្នាក់នៅមណ្ឌលអប់រំកែប្រែទី២។

ការថែទាំសុខភាពនៅមុន និងក្រោយពេលសម្រាលកូនក្នុងពន្ធនាគារគឺមានលក្ខណៈខ្វះខាតយ៉ាងខ្លាំង ហើយស្ត្រីពុំបានចូលរួមក្នុងកម្មវិធីរៀនសូត្រ អំពីរបៀបថែទាំងខ្លួនក្នុងកំឡុងពេលមានផ្ទៃពោះព្រមទាំងរបៀបសម្រាលកូន និងរបៀបបំបៅដោះកូនក៏ដូចជា ការថែទាំទារកក្រោយពេលសម្រាលផងដែរ។ សូម្បីតែស្ត្រីមានផ្ទៃពោះ ដែលបានផ្តល់សម្ភាសន៍សុទ្ធតែមានចេតនាទុកកូននៅក្នុងពន្ធនាគារបន្ទាប់ពីសម្រាលកូនរួច ប៉ុន្តែគ្មានស្ត្រីណាម្នាក់បានទទួលការអប់រំអំពីរបៀបថែទាំទារកឡើយ ហើយតម្រូវឱ្យមានការថែទាំងសុខភាពនៅមុន និងក្រោយពេលសម្រាលកូនឱ្យបានកាន់តែប្រសើរជាងនេះថែមទៀត ដើម្បីធានាឱ្យស្ត្រីមានជំនាញក្នុងការថែទាំផ្នែកសុខភាព និងអារម្មណ៍ដែលពួកគេត្រូវការ។

## ការជួបគ្រួសារ

ស្ត្រី ៦៥% ដែលបានផ្តល់សម្ភាសន៏ បានលើកឡើងថា ពួកគេពុំដែលបានទទួលការជួយឧបត្ថមពីគ្រួសារទេ ហើយ ៣៥% ទៀតពុំដែលមានទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេទាល់តែសោះ។ កង្វះការជួយឧបត្ថម្ភគាំទ្រពីសំណាក់គ្រួសារ ស្ត្រីមិនអាចមានម្ហូបអាហារ ឬ ថ្នាំពេទ្យបន្ថែមគ្រប់គ្រាន់សម្រាប់កូនៗរបស់ពួកគេឡើយ។

## ពេលវេលាចេញក្រៅបន្ទប់ឃុំឃាំង

ពេលវេលាចេញក្រៅបន្ទប់ គឺជាកត្តាសំខាន់សម្រាប់សុខភាព និងសុខមាលភាពរបស់អ្នកទោស និងកូនៗរបស់ពួកគេ។ ការចេញក្រៅនេះរួមទាំងពេលវេលាដែលអ្នកទោស និងកូនៗរបស់ពួកគេអាចចូលរួមក្នុងសកម្មភាពពេញលេញ ការអប់រំ ការលេងកំសាន្ត ការងារ និងកម្មវិធីរៀបចំអាកប្បកិរិយាជាដើម ក្រៅពីនេះក៏មានពេលវេលាសម្រាប់ហាត់ប្រាណ ហូបចុកចំណីអាហារ ចូលរួមសកម្មភាពជាមួយអ្នកទោសដទៃទៀត និងធ្វើសកម្មភាពជាមូលដ្ឋានផ្សេងៗដូចជា ងូតទឹក ប្រើប្រាស់ទូរស័ព្ទ ហាលសម្លៀកបំពាក់ និងការងារកាត់ដេរសម្រាប់ពន្ធនាគារជាដើម[៤]។

ស្ត្រី ៨២% ដែលបានផ្តល់សម្ភាសន៏ចំណាយពេលវេលាពី ១៩ ទៅ ២៤ ម៉ោងនៅក្នុងបន្ទប់ឃុំឃាំង។ មានតែស្ត្រី១៨% ប៉ុណ្ណោះដែលចំណាយពេលជាង ៥ ម៉ោងប៉ុណ្ណោះនៅក្រៅបន្ទប់ឃុំឃាំងជាមួយកូនៗរបស់ពួកគេ ហើយស្ត្រី ១១ % ទៀតមិនដែលបានចេញក្រៅបន្ទប់ឃុំឃាំងទាល់តែសោះ។

---

[៤] ស្ត្រីទាំងនេះធ្វើការឱ្យពន្ធនាគារ ប៉ុន្តែយើងមិនច្បាស់ថាតើពួកគេបានទទួលប្រាក់កម្រៃ ឬ ក៏អត់ទេចំពោះការងារនេះ




# ការអប់រំ

## *ការទទួលបានការអប់រំ*

ស្រ្តីជាម្តាយរស់នៅក្នុងពន្ធនាគារជាមួយកូនដែលមានអាយុជាង ៤ ឆ្នាំ សង្កេតឃើញថា ខ្វះការអប់រំ គឺជាបញ្ហាដ៏ធំបំផុតដែលកុមារប្រឈមមុខនៅក្នុងពន្ធនាគារ។ ស្រ្តីជាម្តាយភាគច្រើននៅក្នុងពន្ធនាគារគឺជាមនុស្សមិនចេះអក្សរ ហើយដូច្នេះ មិនអាចបង្រៀន និងអប់រំកូនបានទេ ។

> *"កូនខ្ញុំចេះតែធំឡើងពីមួយថ្ងៃទៅមួយថ្ងៃ ហើយពុំមានអនាគតល្អទេ ពីព្រោះវាមិនចេះអក្សរ"* ។ សម្តីម្តាយនៅពន្ធនាគារតាខ្មៅ។

គម្រោងផ្តល់ជំនួយដល់កុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយបច្ចុប្បន្នពុំទាន់បានជួយកុមារឱ្យទទួលបានការអប់រំ និងពេលវេលាលេងកំសាន្តឡើយ ប៉ុន្តែការអប់រំ លេងកំសាន្ត និងកម្មវិធីអប់រំមួយចំនួន ត្រូវបានបង្កើតសម្រាប់កុមារនៅក្នុងមណ្ឌលអប់រំកែប្រែទី២ តាមរយៈអង្គការមិនមែនរដ្ឋាភិបាលមួយដែលមិនធ្វើការសម្របសម្រួលជាមួយគម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ។ ពេលព្រឹកកុមារទៅរៀនថ្នាក់មតេយ្យ ហើយពេលល្ងាចទើបត្រឡប់ទៅវិញ ដែលធ្វើឱ្យកុមារទាំងនោះ មានឱកាសនៅក្រៅបន្ទប់ឃុំឃាំងរហូត ៦ ម៉ោងក្នុងមួយថ្ងៃ ដែលពួកគេអាចលេងជាមួយកុមារដទៃទៀត ព្រមទាំងទទួលបាននូវការអប់រំតាំងពីវ័យកុមារតូច។

ខណៈដែលកុមារជិតដល់អាយុចូលរៀន ការទទួលបានការអប់រំ និងពេលវេលាលេងកំសាន្តនៅក្នុង

ពន្ធនាគារក្លាយជាកត្តាកំណត់មួយយ៉ាងសំខាន់ថា តើស្ត្រីជាម្តាយជ្រើសរើសយកការរក្សាទុកកូននៅក្នុងពន្ធនាគារជាមួយពួកគេ ឬ អត់។

ជារឿយៗការអប់រំត្រូវបានបញ្ជាក់ថា ជាមូលហេតុសម្រាប់ឱ្យកុមារចាកចេញពីពន្ធនាគារ។ អាស្រ័យដោយពុំមានកម្មវិធីអប់រំនៅក្នុងពន្ធនាគារសម្រាប់កុមារ ស្ត្រីជាម្តាយទាំងឡាយត្រូវបង្ខំចិត្តជ្រើសរើសរវាងការបញ្ជូនកូនចេញក្រៅពន្ធនាគាររស់នៅជាមួយមិត្តភ័ក្ត សាច់ញាតិ អង្គការមិនមែនរដ្ឋាភិបាល ឬ មណ្ឌលកុមារកំព្រាដើម្បីបានទៅរៀននៅក្រៅពន្ធនាគារ ឬ បន្តទុកកូននៅក្នុងពន្ធនាគារដោយពុំបានទៅរៀនសោះ។ នេះ គឺជាបញ្ហាស្មុគស្មាញមួយដែលស្ត្រីទាំងនោះ ពិបាកធ្វើសេចក្តីសម្រេចចិត្តដោយហេតុថាពុំមានការធានាណាមួយថា កុមារនឹងបានចូលរៀនទេនៅពេលចេញពីពន្ធនាគារ។ ស្ត្រីជាម្តាយម្នាក់នៅពន្ធនាគារខេត្តសៀមរាបបាននិយាយថា កូនរបស់ខ្លួនរស់នៅជាមួយស្វាមីរបស់ខ្លួន ដែលមានប្រពន្ធក្រោយ ហើយនាងត្រូវធ្វើផ្ទះសព្វមុខទាំងអស់ដោយពុំបានទៅរៀនទេ។ ការខ្វាយខ្វល់អំពីសុវត្ថិភាពរបស់កូននៅក្រៅពន្ធនាគារក៏ធ្វើឱ្យម្តាយខ្លះមានការស្ទាក់ស្ទើរក្នុងការបញ្ជូនកូនចេញទៅក្រៅពន្ធនាគារផងដែរ។



*ស្ត្រី និងកុមារ នៅមណ្ឌលអប់រំកែប្រែទី ២ នាទិវាសិទ្ធិស្ត្រី អន្តរជាតិ ២០០៩*

អាស្រ័យដោយពុំបានមើលថែទាំកូនដោយខ្លួនឯង ម្តាយទាំងឡាយសម្តែងនូវការខ្វាយខ្វល់ខ្លាចក្រែងកូនរបស់ខ្លួនត្រូវទទួលរងនូវការរំលោភបំពាន ឬ ពុំមានការយកចិត្តទុកដាក់ ដែលនាំឱ្យមានការរើសអើង ឬ ត្រូវគ្រូ ឬ កុមារដូចដទៃសម្លុត ពីព្រោះតែម្តាយរបស់គេជាប់នៅពន្ធនាគារ ទាំងនេះគឺជាមនោសញ្ចេតនាដែលសម្តែងចេញដោយប្រធានពន្ធនាគារមួយចំនួន។ ម្តាយមួយចំនួនបានលើកឡើងប្រសិនបើកូនៗរបស់ពួកគេ ត្រូវបានអនុញ្ញាតទៅសាលារៀននៅខាងក្រៅពន្ធនាគារនៅពេលថ្ងៃ ហើយយប់ឡប់មករស់នៅជាមួយពួកគាត់ក្នុងពន្ធនាគារវិញនោះនឹងអាចកាត់បន្ថយនូវបញ្ហាបានមួយភាគធំ។ ប៉ុន្តែប្រធានពន្ធនាគារម្នាក់បានសម្តែងនូវការព្រួយបារម្ភថា ប្រសិនបើបញ្ជូនកុមារឱ្យទៅរៀនសាលាខាងក្រៅបរិវេណពន្ធនាគារ កុមារទាំងនោះអាចវង្វេងផ្លូវ ឬ រងគ្រោះថ្នាក់តាមផ្លូវដោយហេតុថា ពុំមានអ្នកណាជួយមើលការខុសត្រូវកុមារទាំងនោះទេនៅខាងក្រៅពន្ធនាគារ ។ សម្ភារៈសិក្សាដូចជា ប៊ិច សៀវភៅ និងឯកសណ្ឋានសាលាត្រូវបានគិតថា ជាឧបសគ្គមួយដែលរារាំងកុមារទាំង នោះមិនឱ្យទៅសាលាបានដោយងាយ។ ម្តាយមួយចំនួននិយាយថា ពួកគេចង់ឱ្យកូនទៅរៀន ប៉ុន្តែពុំមានលទ្ធភាព ទិញសម្ភារៈសិក្សាឱ្យកូនទេ។ កង្វះកង់ដែលជាមធ្យោបាយធ្វើដំណើរជាការលំបាកមួយដល់កុមារ ដែលត្រូវបានអនុញ្ញាតឱ្យទៅសាលាក្រៅពន្ធនាគារមិនអាចទៅរៀនបានទៀងទាត់រាល់ថ្ងៃទេដោយសាលានៅឆ្ងាយពីពន្ធនាគារ។

### *ចំណេះដឹងទូទៅ*

ស្ត្រីជាម្តាយភាគច្រើនមិនអាចអប់រំកូនរបស់ខ្លួនអំពីជីវិតនៅក្រៅពន្ធនាគារបានទេ។ លើសពីនេះទៀត កុមារដែលធំដឹងក្តីឡើងនៅក្នុងពន្ធនាគារ ចៀសមិនផុតពីការខ្វះចំណេះដឹងទូទៅឡើយ។ ជាធម្មតាកុមារដែលរស់នៅក្នុងស្ថាប័នណាមួយច្រើនតែជួបប្រទះនូវការខ្វះចំណេះដឹងទូទៅអំពីសង្គម ហើយការសិក្សាបានផ្សារភ្ជាប់បញ្ហានេះជាមួយកង្វះលទ្ធភាពក្នុងការស្វែងរកទីកន្លែងឱ្យបានសមរម្យនៅក្នុងសង្គម នៅពេលដែលកុមារធំពេញវ័យ[៥]។ កុមារដែលធំដឹងក្តីនៅក្នុងស្ថាប័នណាមួយច្រើនតែពុំសូវមានចំណេះដឹងជាមូលដ្ឋានដូចជា ការទិញដូរនៅផ្សារ ឬមានអាកប្បកិរិយាឆ្គាំឆ្គងនៅក្នុងសង្គមដោយមិនសូវដឹងថាត្រូវរៀបចំឬកពារដូចម្តេចនៅក្នុងសង្គម។ ការលើកឡើងបែបនេះហាក់ដូចជាត្រឹមត្រូវ ហើយវាកាន់តែច្បាស់ជាងនេះទៅទៀតនោះគឺ គេសង្កេតឃើញថា កុមារជាច្រើនដែលធំដឹងក្តីឡើងក្នុងពន្ធនាគារមិនចេះអានអក្សរទេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារបានផ្តល់កុមារនូវសិទ្ធិចូលរួមក្នុងវប្បធម៌សង្គមរបស់ខ្លួន។ កុមារតូចៗរស់នៅក្នុងពន្ធនាគារពុំអាចមានលទ្ធភាពក្នុងការចូលរួមបែបនេះទេ ហើយបញ្ហានេះអាចជាប់ពាក់ព័ន្ធជាមួយនឹងអនាគតរបស់ពួកគេយ៉ាងយូរអង្វែង។ នេះក៏ជាបញ្ហាមួយពិតផងដែរចំពោះកុមារណាដែលម្តាយមកពីប្រទេសផ្សេង ដោយកុមារពុំមានឱកាសរៀនភាសាកំណើតរបស់ខ្លួនបានឡើយ ហើយនេះជាឧបសគ្គមួយក្នុងការទំនាក់ទំនងនៅពេលដែលកុមារត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ។

## ការលេងកំសាន្ត

កុមាររស់នៅក្នុងពន្ធនាគារត្រូវបានគេពិពណ៌នាថា បានចូលរួមក្នុងសកម្មភាពលេងកំសាន្តជាលក្ខណៈច្នៃប្រឌិត ល្បែងកំសាន្តពង្រឹងរាង្គកាយជាច្រើនដូចជា ឆាកសម្តែងពីជីវភាពប្រចាំថ្ងៃ និងលេងទាត់បាល់ ឬ ល្បែងប្រជាប្រិយខ្មែរមួយចំនួនទៀត។ អាស្រ័យដោយពុំមានសម្ភារៈលេងឱ្យបានត្រឹមត្រូវ កុមារមួយចំនួនលេងជាមួយប្រដាប់ប្រដាដែលអ្នកទោសផលិតឡើង ឬ លេងរបស់របរទូទៅដូចជា ចាន ឆ្នាំងជាដើម។

ជាទូទៅ ម្តាយជាច្រើននិយាយថា កូនៗរបស់ពួកគេពុំមានមិត្តភ័ក្តលេងជាមួយទេ។ គេនិយាយថា ជារឿយៗម្តាយ និងអ្នកទោសដទៃៗទៀតតែងតែលេងជាមួយកុមារ ប៉ុន្តែនេះក៏នៅតែពុំទាន់គ្រប់គ្រាន់នៅឡើយដែរ ។ ទោះបីជាមានសេចក្តីរាយការណ៍ថា កុមារភាគច្រើនលេងជាមួយគ្នានៅក្នុងពន្ធនាគារក៏ដោយ ក៏ពួកគេកម្រលេងជាមួយកូនៗរបស់ឆ្មាំពន្ធនាគារណាស់។ តាមការសិក្សាបានឱ្យដឹងថា កុមារ ៨៤% លេងជាមួយគ្នាទៅវិញ

---

[៥] Tizard, B., & Hodges, J. (1978). "ផលប៉ះពាល់ដល់ការលូតលាស់របស់កុមារអាយុ ៨ ឆ្នាំ ដោយសារការចិញ្ចឹមនៅក្នុងស្ថានប័នណាមួយ " ទិន្នានុប្បវត្តិចិត្តវិទ្យាកុមារ និងចិត្តសាស្រ្ត Vol 19 ទំ. ៩៩ - ១១៨ ។

ទៅមក ប៉ុន្តែ ១៦%ផ្សេងទៀតពុំបានលេងដូច្នេះទេ។ ហើយចំណុចមួយគួរឱ្យកត់សំគាល់នោះគឺថា មានកុមារតែ មានកុមារតែ ១៣.៥% ប៉ុណ្ណោះដែលបានលេងជាមួយកូនៗរបស់ឆ្មាំពន្ធនាគារ។

អ្នកខ្លះមានអារម្មណ៍ថា កុមារនៅក្នុងពន្ធនាគារទាំងនោះ ពុំមានកន្លែងគ្រប់គ្រាន់សម្រាប់លេងទេ។ កុមារខ្លះជាប់នៅក្នុងបន្ទប់ឃុំឃាំងយ៉ាងយូរ ជាកន្លែងចង្អៀតណែន ក្តៅខ្លាំង និងថប់ដង្ហើម។

មណ្ឌលអប់រំកែប្រែទី២ គឺជាពន្ធនាគារតែមួយគត់ដែលផ្តល់សម្ភារៈសម្រាប់លេងដល់កុមារ ព្រមទាំងអនុញ្ញាតឱ្យកុមារទាំងនោះទៅរៀនមតេយ្យ ៨ម៉ោងក្នុងមួយថ្ងៃ។ អង្គការ NAAA បានកសាងសាលាមតេយ្យរួចរាល់ហើយនៅពន្ធនាគារខេត្តសៀមរាប ហើយកំពុងសុំការអនុញ្ញាតដើម្បីចាប់ផ្តើមបវេសនកាលថ្មី (ពេលនេះទទួលបានហើយ)។ កន្លងមក ពុំទាន់ឃើញមានពន្ធនាគារណាមួយដែលគម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារនេះ មានសាលាមតេយ្យ និងផ្តល់ការលេងកំសាន្តដល់កុមារឡើយ។

ម្តាយទាំងឡាយបានស្វាគមន៍នូវឱកាសសម្រាប់កុមារលេង និងកំសាន្តនៅខាងក្រៅបន្ទប់ពន្ធនាគារ ហើយចាត់ទុកថាជាកត្តាសំខាន់ណាស់សម្រាប់ការធំធាត់លូតលាស់របស់កុមារម្នាក់ៗ ។ ការសិក្សាជាលក្ខណៈអន្តរជាតិបានបង្ហាញឱ្យឃើញតាំងពីយូរណាស់មកហើយថា ការលេងកំសាន្តគឺជាកត្តាមួយសំខាន់នៃការលូតលាស់របស់កុមារ[៦] ។ ការលេងជួយឱ្យកុមាររៀនសូត្រនូវជំនាញចាំបាច់ផ្នែករាងកាយ និងប្រាជ្ញាសម្រាប់ការលូតលាស់ធម្មតា ហើយកង្វះការលេងនេះ កុមារអាចមានបញ្ហាលូតលាស់យឺត។

ផ្នែក ៣.៩ នៃសៀវភៅប្រតិបត្តិសុខភាពនៅក្នុងពន្ធនាគាររៀបរាប់អំពីនីតិវិធីសមរម្យសម្រាប់ "ថែទាំកុមារតូចៗនៅក្នុងពន្ធនាគារ"។ នីតិវិធីនោះ បានរៀបចំនូវប្រព័ន្ធ និងវិធីសាស្ត្រវាយតម្លៃសុខមាលភាពកុមារនីមួយៗ និងមានការរៀបចំជាផែនការអភិវឌ្ឍសកម្មភាពសម្រាប់ការលូតលាស់ដែលមាន "អាយុជាក់លាក់ និងតម្រូវការអារម្មណ៍"។ ពុំមានប្រធានពន្ធនាគារ ឬ អ្នកទោសណាម្នាក់លើកឡើងអំពីទម្រង់នៃការវាយតម្លៃ ឬផែនការណាមួយសម្រាប់កុមារឡើយ។ កុមារតូចៗនៅក្នុងពន្ធនាគារកម្ពុជាបានធំធាត់ឡើង ដោយមានការលេង រៀនសូត្រ និងលូតលាស់តិចតួចបំផុត ដោយហេតុនេះហើយ ពុំបានស្របទៅតាមក្របខណ្ឌនៃរាជរដ្ឋាភិបាលកម្ពុជា និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។

---

[៦] សារៈសំខាន់នៃការលេងក្នុងការលើកកម្ពស់ការលូតលាស់របស់កុមារមានសុខភាពល្អ និងរក្សាបាននូវចំណងរវាងឪពុកម្តាយ និងកូនបានរឹងមាំ "Ginsburg MD, K ។របាយការណ៍គ្លីនិក។ បណ្ឌិតសភាពេទ្យកុមារអាមេរិក- ពេទ្យកុមារ (២០០៧) Vol 119 លេខ ១. ទំ. ១៨២-១៩១ - Mc.Donald, K., & Park,R. Bridging Gap: ។ ការលេងរវាងឪពុកម្តាយ និងកូន និង ការលេង ជាមួយក្មេងដូចគ្នា។ "ការអភិវឌ្ឍកុមារ" (១៩៨៤)Vol ទំ. ១២៦៥-១២៧៧។

## ការរំលោភបំពាន

ស្ត្រីជាម្ដាយមួយចំនួនបានរាយការណ៍ថា កូន១របស់ពួកគាត់បានរងនូវការរំលោភលើរាង្គកាយពីសំណាក់ឆ្មាំ និងអ្នកទោសផ្សេង១ទៀត។ របាយការណ៍ស្ដីការរំលោភលើរាង្គកាយ និងការឈឺចាប់ផ្នែកអារម្មណ៍របស់កុមារក្នុងពន្ធនាគារ វាគ្រាន់តែជួយគូសបញ្ជាក់នូវតម្រូវការទីកន្លែងមួយដែលមានសុវត្ថិភាពសម្រាប់កុមារនៅក្នុងពន្ធនាគារ ដែលពួកគេអាចលេង និងចៀសផុតពីការរំលោភបំពាន និងធ្វើបាបនានាតែប៉ុណ្ណោះ។

មាត្រា ១៩ នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារបានធ្វើការកត់សំគាល់ថា "រដ្ឋភាគីនានាត្រូវចាត់វិធានការច្បាប់រដ្ឋបាល សង្គម និងវិធានការអប់រំនានាដើម្បីការពារកុមារពីរាល់ទម្រង់នៃអំពើហិង្សាលើរាង្គការ និងផ្លូវចិត្ត របួស ឬ ការរំលោភ ភាពព្រងើយកន្តើយ ឬ ការប្រព្រឹត្តិដោយមិនយកចិត្តទុកដាក់ ការប្រព្រឹត្តិឃោរឃៅ ឬ ការកេងប្រវ័ញ្ច"។ ប៉ុន្តែ នៅពន្ធនាគារកម្ពុជា កុមារតូច១បានរងគ្រោះពីភាពព្រងើយកន្តើយ និងជាជនរងគ្រោះពីការរំលោភលើផ្នែករាង្គកាយនិងអារម្មណ៍។ រដ្ឋភាគីជាច្រើនពុំបានធ្វើអន្តរាគមន៍ទប់ស្កាត់បញ្ហានេះទេ ហើយមានករណីខ្លះទៀត រដ្ឋទាំងនោះជាអ្នកទទួលខុសត្រូវចំពោះបញ្ហាថែមទៀត ពេលដែលកងសន្តិសុខរដ្ឋាភិបាលសម្លុត ឬ វាយកុមារ។

មាត្រា ១៩ ក៏បានធ្វើការកត់សំគាល់ផងដែរថា រដ្ឋភាគីជាអ្នកទទួលខុសត្រូវចំពោះការស្នើឡើងនូវ "កម្មវិធីដើម្បីផ្ដល់ការគាំទ្រចាំបាច់នានាសម្រាប់កុមារ និងសម្រាប់អ្នកដែលមានតួនាទីមើលថែទាំកុមារ ក៏ដូចជាសម្រាប់ទម្រង់នៃការទប់ស្កាត់នានា និងសម្រាប់កំណត់នូវអត្តសញ្ញាណ ការរាយការណ៍ និងការបញ្ជូនជាដើម។ នៅក្នុងពន្ធនាគារពុំឃើញមានយន្តការណាមួយសម្រាប់កំណត់អត្តសញ្ញាណ ឬ រាយការណ៍អំពីអំពើព្រងើយកន្តើយ និងរំលោភបំពាន និងពុំមាននីតិវិធីច្បាស់លាស់សម្រាប់បញ្ជូនផងដែរ។ ជាងនេះទៅទៀត រដ្ឋាភិបាលក៏ពុំបានស្នើឡើងឱ្យមានកម្មវិធីសង្គមណាមួយដើម្បីជួយស្ត្រីជាម្ដាយ និងកុមារនានាដើម្បីទប់ស្កាត់ការរំលោភបំពានឡើយ។

# ៥. ទិសដៅអនាគត

## បញ្ហាសំខាន់ៗ

ខណៈដែលការពិនិត្យឡើងវិញនូវគម្រោងផ្តល់ជំនួយដល់កុមាររស់នៅជាមួយម្តាយក្នុងពន្ធនាគារ វាបានបង្ហាញឱ្យឃើញច្បាស់ថា គម្រោងនេះបានជួយផ្តល់ម្ហូបអាហារ ទឹក សម្លៀកបំពាក់ និងការថែទាំសុខភាពដែលជាតម្រូវការចាំបាច់យ៉ាងច្រើនឱ្យដល់កុមារម្តាយ និងស្ត្រីមានផ្ទៃពោះ ស្ត្រីជាច្រើនក៏នៅតែមានការខ្វាយខ្វល់អំពីកង្វះខាតម្ហូបអាហារ និងទឹក សេវាកម្មសុខភាព ក៏ដូចជាការអប់រំ ។

ការទទួលបាននូវម្ហូបអាហារដែលមានសារធាតុចិញ្ចឹម ទឹក ប្រដាប់ប្រដាសម្រាប់លេង និងការថែទាំសុខភាពគឺជាការខ្វាយខ្វល់យ៉ាងខ្លាំងរបស់ស្ត្រីមានផ្ទៃពោះ និងស្ត្រីជាម្តាយដែលមានកូនអាយុតិចជាង ៤ ឆ្នាំ ចំណែកឯម្តាយដែលមានកូនធំជាងនេះវិញ មានការខ្វាយខ្វល់ខ្លាំងអំពីការអប់រំរបស់កូនៗពួកគេ ។

ជាការឆ្លើយតបទៅនឹងការខ្វាយខ្វល់នេះ ស្ត្រីជាច្រើនបានអំពាវនាវឱ្យមានមណ្ឌលសុខភាព និងសាលារៀននៅក្នុង ឬ ជិតៗបរិវេណពន្ធនាគារ ដូច្នេះកុមារៗអាចប្រើប្រាស់សេវាទាំងនេះ ដោយមិនចាំបាច់ឃ្លាតឆ្ងាយពីម្តាយរបស់ពួកគេ ។

ប្រធានពន្ធនាគារក៏បានលើកឡើងស្រដៀងគ្នាជាមួយនឹងស្ត្រីជាម្តាយដែរ ។ ពួកគាត់មានការខ្វាយខ្វល់យ៉ាងខ្លាំងអំពីកង្វះអាហារដែលមានសារធាតុចិញ្ចឹម ហើយរដ្ឋាភិបាលបានសន្យាតាមការស្នើសុំថវិកាសម្រាប់អាហារបន្ថែមសម្រាប់កុមារស្ត្រីបំបៅដោះកូននឹងទឹកដោះគោបន្ថែមសម្រាប់ទារកតូចៗ ។ មានប្រធានពន្ធនាគារខ្លះទៀតបានស្នើសុំឱ្យរដ្ឋាភិបាលធ្វើការផ្គត់ផ្គង់អាហារឱ្យបានទាន់ពេល ។ ប្រធានពន្ធនាគារជាច្រើនក៏មានការខ្វាយខ្វល់អំពីបញ្ហាសុខភាពដែរ ហើយប្រធានពន្ធនាគារខេត្តកំពង់ឆ្នាំងចង់មានបុគ្គលិកពេទ្យប្រចាំការ "២៤ម៉ោង និងចង់មានមណ្ឌលសុខភាព" ដើម្បីផ្តល់ការព្យាបាលឱ្យបានប្រសើរជាងមុន ព្រមទាំងជួយដល់កុមារ និងម្តាយនៅក្នុងពន្ធនាគារ ។

ប្រធានពន្ធនាគារជាច្រើនក៏បានគាំទ្រចំពោះកម្មវិធីសិក្សាសម្រាប់កុមារនៅក្នុងពន្ធនាគារផងដែរ ។ប្រធានពន្ធនាគារមួយចំនួនបានអំពាវនាវរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីបើកមណ្ឌលអប់រំ និងមានប្រធានពន្ធនាគារម្នាក់រហូតដល់ស្នើឱ្យមានទាំងថ្នាក់មតេយ្យ និងបឋមសិក្សា ។ ប្រធានទាំងនោះក៏បានបង្ហាញនូវការខ្វាយខ្វល់អំពីកង្វះប្រដាប់ប្រដា និងកន្លែងសម្រាប់កុមារលេងផងដែរ ។ ប្រធានពន្ធនាគារខេត្តសៀមរាបគិតថា ទាំងអស់នេះអាចធ្វើទៅបាន គឺដោយកសាងអគារបន្ថែមសម្រាប់កុមារស្នាក់នៅ និងលេងគ្រប់គ្រាន់ហើយ ។

ប្រធានពន្ធនាគារមួយចំនួនបានគាំទ្រកម្មវិធីអប់រំ និងបណ្តុះបណ្តាលសម្រាប់ស្ត្រីជាម្តាយនៅក្នុងពន្ធនាគារ នូវប្រធានបទដូចជា បំណិនជីវិត ការលូតលាស់របស់កុមារ សុខភាព និងអនាម័យជាដើម ។

## ការពង្រីកគម្រោងផ្តល់ជំនួយដល់កុមាររស់នៅក្នុងពន្ធនាជាមួយម្តាយ

### *កែលំអរសេវាកម្មដែលមានស្រាប់*

លីកាដូ និងហ្វូរីហ្សុន មានគោលបំណងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយម្ចាស់ជំនួយដើម្បីកែលំអរ បញ្ហាម្ហូបអាហារ សម្លៀកបំពាក់ និងសេវាកម្មសុខភាពដែលលើកឡើងខាងលើ ព្រមទាំងអនុវត្តនូវកម្មវិធីអប់រំ សម្រាប់កុមារ ដែលរស់នៅក្នុងពន្ធនាគារ និងជួយឧបត្ថម្ភដល់ម្តាយ និងកុមារដែលចាកចេញពីពន្ធនាគារ ។

### *ការរៀបចំកម្មវិធីសិក្សា*

កុមារជាង ៩០% នៅក្នុងពន្ធនាគារមានអាយុ ចាប់ពី ៤ ដល់ ៧ ឆ្នាំ ហើយតាមច្បាប់កុមារអាចនៅជា មួយម្តាយក្នុងពន្ធនាគារត្រឹមអាយុ ៦ ឆ្នាំ តែប៉ុណ្ណោះ (ហើយក៏មានប្រធានពន្ធនាគារខ្លះនិយាយថា គេធ្លាប់ បានអនុញ្ញាតឱ្យកុមារខ្លះ ស្នាក់នៅជាមួយម្តាយរហូត ដល់អាយុលើសពី ៦ ឆ្នាំទៅទៀត ពីព្រោះម្តាយពុំមាន កន្លែងឱ្យកូនស្នាក់នៅ) ។ កុមារទាំងនោះ ក្នុងពេល ឆាប់ៗ ខាងមុខនឹងត្រូវដល់អាយុចូលរៀននៅតាមសា លា។ កុមារជាធម្មតាចូលរៀននៅបឋមសិក្សាចាប់ ពីអាយុ ៦ ឆ្នាំ ហើយនៅពន្ធនាគារខេត្តបាត់ដំបង និង ពន្ធនាគារខេត្តបន្ទាយមានជ័យ គឺជាពន្ធនាគារដែលបាន អនុញ្ញាតឱ្យកុមារចេញទៅរៀននៅថ្នាក់បឋមសិក្សា។ នៅក្នុងពន្ធនាគារខេត្តបាត់ដំបង តាមរយៈការជួយ ឧបត្ថម្ភពីអង្គការ NAAA ដែលចេញចំណាយក្នុងការបញ្ជូន កុមារម្នាក់ទៅរៀននៅសាលាបឋមសិក្សាខាងក្រៅ។ នៅកម្ពុជាកុមារ៨៩%បានចូលរៀនថ្នាក់ទី១ នៅអាយុ ៦ ឆ្នាំ[៧] ដូច្នេះកុមារណាដែលខកខានមិនបានចូលឆ្នាំនេះ ត្រូវខាតពេល។

ដូចដែលបានលើកឡើងពីខាងដើម ស្ត្រីជាម្តាយភាគច្រើនមានអារម្មណ៍ច្របូកច្របល់អំពីបញ្ហាថា តើត្រូវ ទុកកូននៅក្នុងពន្ធនាគាជាមួយខ្លួន ឬមិនគួរទុកទេ។ ម្តាយទាំងនោះពិតជាចង់ទុកកូនឱ្យនៅជាមួយខ្លួនខ្លាំងណាស់ ប៉ុន្តែបារម្ភអំពីផលប៉ះពាល់ដល់អនាគតរបស់ពួកគេ។ ស្ត្រីជាម្តាយមួយចំនួនធំ ពុំទាន់បានគិតគូរដល់អនាគតរបស់ កូនខ្លួននៅពេលមានអាយុ ៦ ឆ្នាំ នៅឡើយទេ។ ម្តាយភាគច្រើននិយាយថា គេបានទុកកូនឱ្យនៅជាមួយបែបនេះ ពីព្រោះពុំមានកន្លែងណាផ្សេងសម្រាប់ទុកទេ។ គ្រួសាររបស់ពួកគេក្រីក្រពេក ឬ មិនអាច/មិនចង់យកកូនទៅនៅ ជាមួយដោយសារមូលហេតុផ្សេងៗ។ ម្តាយទាំងនោះក៏គិតថា ទៅថ្ងៃក្រោយក៏អាចមានបញ្ហាបែបនេះដែរ ហើយ

---

[៧] កម្ពុជា ២០០៧-បាយការណ៍វិភាគស្ថានការណ៍ UNICEF: hppt://www.unicef.org/about/execboad/files/2010-CRR-Cambodia.pdf, P5

ម្តាយភាគច្រើនបាននិយាយថា ពួកគេមិនដឹងនឹងត្រូវដោះស្រាយបែបណាទេនៅពេលដែលកូនរបស់ខ្លួនត្រូវចាកចេញពីពន្ធនាគារ ។

អាស្រ័យដោយពុំមានអ្នកណាជួយមើលកូននៅខាងក្រៅ និងជួយផ្តល់ការអប់រំ ម្តាយទាំងនោះពុំសូវមានជំរើសច្រើនទេ ដូច្នេះមានតែយកកូនទៅដាក់នៅក្នុងមណ្ឌលអង្គការ ឬ មណ្ឌលកុមារកំព្រាណាមួយ។ មើលទៅម្តាយទាំងនោះ ហាក់ដូចជាពុំបានដឹងនូវជំរើសណាមួយសម្រាប់កូនៗរបស់ពួកគេទេ ហើយមើលទៅក៏ដូចជាមិនដែលលើកយកបញ្ហាអនាគតរបស់កូនៗនេះទៅពិភាក្សាជាមួយអង្គការដែលជួយឧបត្ថម្ភ ឬ អាជ្ញាធរណាមួយឡើយ។



*កូនរស់នៅជាមួយម្តាយក្នុងពន្ធនាគារខេត្តកោះកុង*

តាមស្រាវជ្រាវថ្នាក់អន្តរជាតិមួយ បានបង្ហាញឱ្យដឹងថា កុមារដែលត្រូវដាក់ឱ្យរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ មណ្ឌលអង្គការណាមួយច្រើនជួបប្រទះបញ្ហាការលូតលាស់យឺតក៏ដូចជារងការរំលោភបំពានលើរាង្គកាយ និងផ្លូវភេទ ហើយមិនសូវចុះសម្រុងនៅក្នុងសង្គមបានដោយស្រួលទេនៅពេលពួកគេធំឡើង[៨]។ ទោះបីជាមានផលប៉ះពាល់ជាអវិជ្ជមាន ដោយសារការឃុំឃាំងមកលើកុមារក៏ដោយ ក៏ស្ត្រីជាម្តាយភាគច្រើននៅតែមានជំនឿថាការបង្កើតឱ្យមានស្ថាប័នមួយសម្រាប់ថែទាំកុមារនៅក្នុងបរិវេណពន្ធនាការ គឺជាជម្រើសមួយដែលល្អសម្រាប់កូនៗរបស់ពួកគាត់។

ប្រធានពន្ធនាគារមួយចំនួនបានកត់សំគាល់ឃើញថា កុមារខ្លះដែលកំពុងរស់នៅក្នុងពន្ធនាគារមានអាយុលើសពី ៨ ឆ្នាំ ហើយថា ពួកគាត់នៅតែអនុញ្ញាតឱ្យកុមារទាំងនោះបន្តស្នាក់នៅជាមួយម្តាយតទៅទៀត ពីព្រោះពុំមានជម្រើសណាផ្សេងពីនេះឡើយ។ អ្នកខ្លះលើកឡើងថា ពុំមានការកំណត់ពេលវេលាទេចំពោះកុមារណាដែលគ្មានអ្នកយកទៅចិញ្ចឹមនៅខាងក្រៅ។

---

[៨] Every Child &Center, R,: បញ្ហាគ្រួសារ : ការសិក្សាអំពីការថែទាំងកុមារក្នុងស្ថាប័ន នៅអឺរុបកណ្តាល និងខាងកើត និងអតីតសហភាពសូវៀត ។(២០០៥) http://p-ced.com/reference/Family_Matters_summary.pdf;
Tizard, B., & Hodges, J, "ផលប៉ះពាល់នៃការចិញ្ចឹមនៅក្នុងស្ថាប័នទៅលើការលូតលាស់របស់កុមារអាយ ៨ ឆ្នាំ" ។ ទិន្នានុប្បវត្តិចិត្តវិទ្យាកុមារ និងសុខភាពផ្លូវភាពចិត្ត (១៩៧៨)" Vol 19 PP 99 -118 Nelson, C., Zeanah, C., Fox, N,Marshall, P., Smyke, A., and Gudhrie, D, "ការស្តារនូវសាច់សារលោហិតឡើងវិញចំពោះកុមារតូចៗ ដែលបានបាត់បង់ជីវភាពសង្គមៈ Bucharest early investment project", Science (2007) Vol 318, pp 1937-1940

ស្របពេលជាមួយគ្នានេះដែរ   ប្រធានពន្ធនាគារច្រើនតែពុំសូវសប្បាយចិត្តក្នុងការឃើញកុមាររស់នៅក្នុងពន្ធនាគារទេ ហើយមានអារម្មណ៍ថា វាជាប្រការមិនយុត្តិធម៌សម្រាប់កុមារទាំងនោះសោះ ។ អ្នកខ្លះលើកឡើងថាពន្ធនាគារអនុញ្ញាតឱ្យកុមារស្នាក់នៅក្នុងករណីដែលម្តាយរបស់ពួកគេគ្មានជម្រើស   ប៉ុន្តែកុមារត្រូវការចូលរៀន ។ ប្រធានពន្ធនាគារយល់ថា ភាគច្រើនស្ត្រីជាម្តាយគ្មានជម្រើស ប៉ុន្តែក៏មិនចង់ទុកកូននៅក្នុងពន្ធនាគារយូរពេកដែរ ។ ការពង្រីកគម្រោងអាចជួយដោះស្រាយតម្រូវការការរៀនសូត្ររបស់កុមារបានភ្លាមៗដោយបញ្ជូនគ្រូទៅបង្រៀនកុមារទាំងនោះក្នុងបរិវេណពន្ធនាគារជាទៀងទាត់  ការផ្តល់សម្ភារៈសិក្សា  ឯកសណ្ឋាន  និងប្រដាប់ប្រដាសម្រាប់លេងជាដើម ។ អង្គការម្ចាស់ជំនួយជាអ្នកដើរតួនាទីសំខាន់ជាងគេបំផុតនៅក្នុងការដោះស្រាយបញ្ហាបែបនេះ ។



*កុមារ និងស្ត្រីនៅមណ្ឌលកែប្រែអប់រំទី ២-ទិវាស្ត្រីអន្តរជាតិ*

***ការបញ្ចូលកុមារជាកូនៗរបស់ឆ្នាំពន្ធនាគារ***

នៅតាមពន្ធនាគារដែលបានចុះទៅធ្វើការសិក្សា មានកុមារដែលជាកូនឆ្នាំពន្ធនាគារចំនួន ៦២ នាក់អាយុក្រោម ១២ ឆ្នាំ ហើយក្នុងចំណោមនោះ កុមារ ៣៤ នាក់អាយុក្រោម ៦ ឆ្នាំ។

ការសិក្សានេះក៏បានសម្ភាសន៍ឆ្នាំពន្ធនាគារជាច្រើននាក់ ដើម្បីចង់ដឹងអំពីលទ្ធភាពក្នុងការបង្កើតកម្មវិធីមួយដែលអាចផ្តល់ផលប្រយោជន៍ដល់កូនៗរបស់ឆ្នាំពន្ធនាគារ និងកូនៗអ្នកទោស។ ក្នុងការផ្តល់ផលប្រយោជន៍ដល់កូនៗរបស់ឆ្នាំពន្ធនាគារ ហើយកម្មវិធីនេះ អាចជួយឱ្យបង្កើតឱ្យមាននូវក្រុមកុមារមួយដែលមានអាយុប្រហាក់ប្រហែលគ្នាសម្រាប់កុមារនៅពន្ធនាគារ ហើយអាចកាត់បន្ថយនូវការអន់ចិត្តរបស់ឆ្នាំពន្ធនាគារទាំងនោះ ចំពោះសេវាកម្មនៃគម្រោងនេះដែលកន្លងមកផ្តល់ឱ្យតែកូនៗអ្នកទោស។

កូនៗរបស់ឆ្នាំពន្ធនាគារភាគច្រើនទៅរៀនតែពេលព្រឹក ហើយត្រឡប់មកផ្ទះនៅម៉ោង ១១។ ប៉ុន្តែកុមារខ្លះរៀនគួរក្រៅម៉ោង ឬ ខ្លះទៅរៀន ១ ខែពេលព្រឹក និង១ខែ ពេលរសៀលតាមការផ្លាស់ប្តូរវេណរបស់សាលា ។ ដោយឆ្នាំពន្ធនាគារភាគច្រើនសុទ្ធតែមានកូនច្រើននាក់ ហើយយើងក៏ពុំទាន់បានដឹងច្បាស់ថា តើមានប៉ុន្មាននាក់ដែលដល់អាយុចូលរៀនក៏ដោយ ប៉ុន្តែតាមមើលទៅកុមារដែលគ្រប់អាយុចូលរៀនថ្នាក់បឋមបានចូលរៀននៅសាលាច្រើនជាង ពួកកុមារដែលទើបតែមានអាយុចូលរៀនថ្នាក់មតេយ្យ។

# ៦. របាយការណ៍ពន្ធនាគារនីមួយៗ

| ពន្ធនាគារ | ស្ត្រីមានកូន | ចំនួនកុមារ | អាយុ (ឆ្នាំ) | អង្គការជួយ | ប្រភេទជំនួយ | អាទិភាពសំខាន់ៗ |
|---|---|---|---|---|---|---|
| ម២ | ៩ | ៩ | 0.១<br>0.៤<br>0.៥<br>១.២<br>១.៥<br>១.៨<br>២.៩<br>៣.៨<br>៤.៦ | ▪ លីកាដូ<br>▪ ស្ថានទូតម៉ាលតា | ▪ លីកាដូ សហការជាមួយដៃគូរដទៃនៅក្នុងនិងក្រៅពន្ធនាគារ និងផ្តល់សេវាសុខភាពផងដែរ ។<br>▪ ស្ថានទូតម៉ាល់តាផ្តល់របបអាហារបន្ថែមរាល់ ២ សប្តាហ៏ម្តង ។ | ស្ត្រីជាម្តាយលើកឡើងថា ផ្តល់របបអាហារបន្ថែម (ត្រី) បានជួយបំពេញតាមតម្រូវការរបស់ម្តាយ និងកូន ។ អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺៈ<br>▪ ទឹកស្អាត និងម្ហូបអាហារគ្រប់គ្រាន់(តាមរបាយការណ៍បានឱ្យដឹងថា របបអាហារនៅឯមណ្ឌលថែទាំពេលថ្ងៃសម្រាប់កុមារត្រូវបានកាត់បន្ថយ) ។<br>▪ អាចទទួលបានជំនួយវេជ្ជសាស្ត្រភ្លាមៗ និងប្រសើរជាងមុន ។<br>លើសពីនេះទៀត ស្ត្រីដែលបានសម្ភាសន៍ក៏មានការខ្វាយខ្វល់ផងដែរអំពីៈ<br>▪ ការឆ្លងជម្ងឺរបេងជាពិសេសកុមារតូចៗដែលត្រូវបានដាក់នៅជិតអគារអ្នកកើតរបេង ។<br>▪ បន្ទប់ឃុំឃាំងគ្មានអនាម័យ និងបរិយាកាសអាប់អួរនាំ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ឱ្យកុមារកាន់តែងាយឆ្លងមេរោគ និងជម្ងឺផ្សេងៗ។ |
| កំពង់ឆ្នាំង | ២ | ២ | ៣<br>៣ | ▪ NAA<br>▪ មនុស្សលោកថ្មី | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះរៀងរាល់ ២ សប្តាហ៍ម្តងតាមរយៈមនុស្សលោកថ្មី។ | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺ:<br>▪ បង្កើនការផ្តល់នូវអាហារមានសារធាតុចិញ្ចឹម និងទឹកស្អាត។<br>▪ ផ្តល់សម្លៀកបំពាក់ ស្បែកជើង និងប្រដាប់លេងបន្ថែមសម្រាប់កុមារ។<br>▪ បង្កើនពេលវេលាសម្រាប់កុមារចេញក្រៅបន្ទប់ឃុំឃាំងដើម្បីចូលថ្នាក់មតេយ្យ និងមានពេលលេងកំសាន្ត។ |
| កំពង់ចាម | ២ | ២ | ០.៥<br>២.៩ | ▪ ជំនួយផ្នែកច្បាប់កម្ពុជា<br>▪ NAAA<br>▪ សង្គ្រោះកុមារអូស្ត្រាលី | ▪ NAAA ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះរាល់ ២ សប្តាហ៍ម្តង ។<br>▪ សង្គ្រោះកុមារអូស្ត្រាលីចូលជួបកុមារម្នាក់ម្តងក្នុង ១ សប្តាហ៍ ដើម្បីផ្តល់ម្ហូបអាហារ និងសម្ភារៈ។ ឈប់ផ្តល់ត្រឹមខែមេសា ២០០៩ ។ | ▪ ម្តាយបានលើកឡើងថាការផ្តល់របបអាហារបន្ថែម(ត្រី) បានជួយបំពេញតាមតម្រូវការសារធាតុចិញ្ចឹមរបស់ម្តាយ និងកូន។<br>អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺ:<br>▪ សេវាកម្មវេជ្ជសាស្ត្រភ្លាមៗ និងសមរម្យជាងមុន។<br>▪ អាហារបន្ថែមសម្រាប់ទារក<br>▪ សម្លៀកបំពាក់ស្បែកជើង និងប្រដាប់លេងបន្ថែមសម្រាប់កុមារ។ |

| | | | | | | |
|---|---|---|---|---|---|---|
| តាខ្មៅ | ៥ | ៦ | 0.១<br>0.២<br>0.២<br>២<br>២<br>៥ | ▪ ស្ថានទូតម៉ាល់តា | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈរាល់ពីរសប្តាហ៍ម្តងដល់ស្ត្រីមានផ្ទៃពោះស្ត្រីមានកូន។ ផ្តល់ជំនួយវេជ្ជសាស្ត្រដល់គ្លីនិកពន្ធនាគារ និងឧបត្ថម្ភថវិកាដល់ស្ត្រីដើម្បីសម្រាលកូននៅមន្ទីរពេទ្យ។ | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺ :<br>▪ សេវាកម្មវេជ្ជសាស្ត្រភ្លាមៗ និងប្រសើរជាងមុន<br>▪ សម្លៀកបំពាក់ ស្បែកជើង និងប្រដាប់លេងសម្រាប់កុមារ ប៉ុន្តែការអប់រំគឺជាអាទិភាពចម្បងបំផុតសម្រាប់ម្តាយដែលមានកូនអាចលើសពី ៥ ឆ្នាំ ពីព្រោះកូនគ្មានកន្លែងរស់នៅ ដូច្នេះត្រូវតែនៅជាមួយម្តាយក្នុងពន្ធនាគារ។ |
| សៀមរាប | ៤ | ៥ | 0.៦<br>១.១១<br>២.៥<br>៣<br>៤ | ▪ NAAA | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះរាល់ ២ សប្តាហ៍ម្តង។ | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាន៍គឺ :<br>▪ សេវាកម្មវេជ្ជសាស្ត្រភ្លាមៗ និង ប្រសើរជាងមុន<br>▪ របបបន្លែបន្ថែម<br>▪ ប្រដាប់លេងសម្រាប់កុមារ |
| ព្រះសីហនុ | ១ | ១ | ១.៩ | ▪ NAAA<br>▪ មូលប់តាប៉ាង | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះរាល់ ២ សប្តាហ៍ម្តង ដែលត្រូវផ្តល់តាមរយៈមូលប់តាប៉ាង ហើយក៏ | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺៈ<br>▪ សម្លៀកបំពាក់ស្បែកជើងសម្រាប់កុមារ<br>▪ ពេលវេលា និងប្រដាប់លេងដើម្បីលើកទឹកចិត្តកុមារឱ្យឆាប់ចេះនិយាយ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ផ្តល់ការបណ្តុះបណ្តាលអំពីការប្រើថ្នាំដល់ស្ត្រីក្នុងពន្ធនាគារ។ | ▪ សេវាសុខភាពសំរាប់ស្ត្រីមានផ្ទៃពោះ |
| កោះកុង | ១ | ១ | ១.៥ | ▪ NAAA | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះ១ ខែម្តង។ | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺៈ<br>▪ របបអាហារមានសារធាតុចិញ្ចឹមបន្ថែម<br>▪ ប្រដាប់លេងសម្រាប់កុមារ |
| ប.មានជ័យ | ៦ | ៧ | ១.១<br>៣<br>៣<br>៤<br>៤<br>៥<br>៧ | ▪ កុមារមេត្តា | ▪ ផ្តល់ម្សៅទឹកដោះគោដល់ម្តាយ (១ខែ ៣ កំប៉ុង/១នាក់) ម្ហូបអាហារ សម្ភារៈ សម្លៀកបំពាក់ និងថ្នាំពេទ្យរាល់ ២ សប្តាហ៍ម្តង និងតាមត្រូវការ (ម្ហូបអាហារ សម្ភារៈ និងថ្នាំផ្តល់គិតជាទឹកប្រាក់ ៥0.000៛ ក្នុង ១ខែ។) | អាទិភាពរបស់ស្ត្រីដែលបានសម្ភាសន៍គឺៈ<br>▪ ផ្តល់ទឹកស្អាត<br>▪ កម្មវិធីអប់រំនៅក្នុងពន្ធនាគារ |
| បាត់ដំបង | ២ | ២ | ៥<br>៦ | ▪ NAAA<br>▪ KnK | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះ ២ ដងក្នុង១ ខែ។<br>▪ NAAA ផ្តល់សម្ភារៈសិក្សា | អាទិភាពចម្បងរបស់ស្ត្រីដែលបានសម្ភាសន៍គឺៈ<br>▪ បង្កើនអនាម័យ សម្ភារៈអនាម័យ និងថ្នាំពេទ្យដើម្បីទប់ស្កាត់ស្ថានភាពស្មោគ្រោក ដូចជាចៃ ជាដើម ។<br>▪ ផ្តល់ទឹកស្អាត |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | យានថ្លៃដឹកជញ្ជូនសម្រាប់កុមារទៅសាលា ។<br>▪ KnK: អ្នកផ្តល់សម្ភាសន៏បាននិយាយថា គេបានជាប់ទាក់ទងអង្គការនេះតាមរយះ NAAA ហើយគេបានផ្តល់ម្ហូបអាហារដល់កុមារ ២ ដង/ខែ ។<br>▪ KnK ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី និងយុវជន។ ទាមរយៈអង្គការនេះ ស្ត្រីបានរៀនកាត់ដេរ ហើយយុវជនរៀនគូរគំនូ និងឆ្លាក់ ។<br>▪ ជួលកាលក៏ជួយឧបត្ថម្ភសម្ភារៈសិក្សា ឬ ការដឹកជញ្ជូនដល់យុវជនដល់យុវជនផងដែរ។ | ▪ ការអប់រំ និងសម្ភារៈសិក្សាដូចជា សៀវភៅ និងឯកសណ្ឋានជាដើម។ |

| | | | | | | |
|---|---|---|---|---|---|---|
| កំពត | ១<br>ស្ត្រីមាន<br>ផ្ទៃពោះ | | | ▪ NAAA | ▪ ផ្តល់ម្ហូបអាហារ និងសម្ភារៈដល់កុមារ និងស្ត្រីមានផ្ទៃពោះ ២ដង/ខែ។ | អាទិភាពរបស់ស្ត្រីដែលបានសម្ភាសន៍គឺ:<br>▪ បង្កើនការផ្តល់ម្ហូបអាហារមានសារធាតុចិញ្ចឹម និង វីតាមីនបន្ថែម។<br>▪ ចង់ជួបគ្រូពេទ្យជាប្រចាំដើម្បីតាមដានផ្ទៃពោះ។ |

# ៧. ការផ្តល់អនុសាសន៍

សេចក្តីត្រូវការរបស់ស្ត្រីមានផ្ទៃពោះ ស្ត្រីជាម្តាយ និងកូនៗរបស់ពួកគេមានលក្ខណៈខុសៗគ្នាពីពន្ធនាគារមួយទៅមួយទៀត ដែលពិបាកក្នុងការផ្តល់អនុសាសន៍រួម។ ដោយយោងទៅនឹងបញ្ហានេះ ម្ចាស់ជំនួយគួរមើលតាមអាទិភាពនៃពន្ធនាគារនីមួយៗដែលមានរៀបរាប់នៅក្នុងតារាងខាងលើ ហើយស្វែងរកមធ្យោបាយនានាដើម្បីធ្វើឱ្យប្រសើរឡើងនូវម្ហូបអាហារ សម្លៀកបំពាក់ ថ្នាំពេទ្យ ព្រមទាំងពង្រីកសេវាកម្មអប់រំ ដែលមានស្រាប់ឱ្យស្របតាមតម្រូវការរបស់កុមារទាំងនោះ។

ប៉ុន្តែ ជាសង្ខេបអ្នកទោសទាំងនោះបានបង្ហាញឱ្យឃើញនូវតម្រូវការចាំបាច់មួយចំនួនដូចខាងក្រោមៈ

- ថ្នាំ វីតាមីន ជាពិសេស ថ្នាំដែលមានជាតិដែកសម្រាប់ស្ត្រីមានផ្ទៃពោះ
- របបអាហារបន្ថែមសម្រាប់ជួយឱ្យស្ត្រីមានផ្ទៃពោះមានទឹកដោះច្រើន និងគាំទ្រពួកគាត់ដោយការជួយបណ្តុះបណ្តាលដោយជំនាញខាងបំបៅដោះកូននឹងត្រូវមានកន្លែងស្ងាត់ និងមានសុវត្ថិភាពសម្រាប់បំបៅដោះកូន។
- មានថ្នាំពេទ្យ និងការព្យាបាលគ្រប់គ្រាន់សម្រាប់ស្ត្រីមានផ្ទៃពោះ ស្ត្រីជាម្តាយ និងកូនៗ។
- កម្មវិធីអប់រំសម្រាប់កុមារដែលមានអាយុពី ៤ ឆ្នាំឡើងទៅ។
- ថ្នាក់មតេយ្យសម្រាប់កុមារដែលមានអាយុចន្លោះពី ២ ទៅ ៤ ឆ្នាំ។
- កន្លែងលេងកំសាន្តដែលមានសុវត្ថិភាពនៅខាងក្រៅបន្ទប់ឃុំឃាំង។
- ប្រដាប់ប្រដាសម្រាប់កុមារលេង លើកទឹកចិត្តឱ្យមានការរៀនសូត្រ និងមានអាកប្បកិរិយាសមរម្យ។

តាមសេចក្តីរាយការណ៍បានឱ្យដឹងថា ក្រោយពីស្រាវជ្រាវនេះ នឹងមានការផ្តល់ម្ហូបអាហារបន្ថែមដល់ស្ត្រី និងកុមារនៅក្នុងពន្ធនាគារ ប៉ុន្តែមកដល់ពេលនេះក៏នៅតែមិនទាន់បានផ្តល់នៅឡើយដែរ។ តម្រូវឱ្យមានការវាយតម្លៃអំពីតម្រូវការថែមទៀតដើម្បីឱ្យដឹងច្បាស់អំពីតម្រូវការនៃអាហារចិញ្ចឹមរបស់កុមារ និងម្តាយ។

http://www.licadho-cambodia.org